FEDERAL COURT OF AUSTRALIA

ASEAN-Australia-New Zealand Free Trade Area (AANZFTA) Economic Cooperation Support Program (AECSP)

# សៀវភៅមូលដ្ឋានសម្រាប់ចៅក្រមអាស៊ានស្តីពីការប្រកួតប្រជែង

បង្កើតឡើងជាផ្នែកនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែងរបស់ AANZFTA
(AANZFTA Competition Law Implementation Program)

## *សេដ្ឋកិច្ចសម្រាប់ចៅក្រមនៅក្នុងបរិបទនៃច្បាប់ប្រកួតប្រជែង*

## 1. សេចក្តីផ្តើម

1.1 សៀវភៅមូលដ្ឋាននេះ មានគោលបំណងដើម្បី៖

a. ធ្វើជាឯកសារផ្អែកលើគោលការណ៍សម្រាប់ការប្រើប្រាស់ដោយសមាជិកតុលាការ ក្នុងរដ្ឋជាសមាជិកនីមួយៗរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (Association of Southeast Asian Nations) (‘ASEAN’)។

b. ផ្តល់នូវមគ្គុទេសក៍ជាក់ស្តែង និងផ្តល់ព័ត៌មានដល់ចៅក្រម ដោយផ្តោតលើការប្រឈម និងបញ្ហាដែលជួបប្រទះនៅក្នុងការវាយតម្លៃភ័ស្តុតាងស្មុគស្មាញពីអ្នកជំនាញក្នុងពេលធ្វើការ និងពិនិត្យសេចក្តីសម្រេចនានាក្រោមច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន និង

c. ជួយក្នុងការអភិវឌ្ឍច្បាប់ប្រកួតប្រជែងពីមុន ដែលបង្កើនភាពច្បាស់លាស់ផ្នែកច្បាប់ លើកកម្ពស់ប្រសិទ្ធភាព និងជំរុញសង្គតិភាព និងភាពអាចព្យាករណ៍បាននៅក្នុងបណ្តារដ្ឋជាសមាជិកអាស៊ាន និងចុងក្រោយ ចូលរួមចំណែកក្នុងការកំណត់គោលនយោបាយការប្រកួតប្រជែងមានលក្ខណៈល្អប្រសើរ។

1.2 សៀវភៅមូលដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃភាពផ្សេងគ្នា និងដំណាក់កាលខុសៗគ្នានៃការរៀបចំច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ សៀវភៅនេះមិនមានបំណងផ្តល់ព័ត៌មានជាក់លាក់ទៅតាមប្រទេសនីមួយៗទេ។

1.3 សៀវភៅមូលដ្ឋាននេះត្រូវបានបង្កើតឡើងដោយចៅក្រមនៃតុលាការសហព័ន្ធអូស្ត្រាលី សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយ OECD។ នេះគឺជាសៀវភៅមួយនៅក្នុងចំណោមសៀវភៅមូលដ្ឋានស្តីពីច្បាប់ប្រកួតប្រជែងជាបន្តបន្ទាប់ដែលត្រូវបានបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់គណៈកម្មការប្រកួតប្រជែងតំបន់ពាណិជ្ជកម្មសេរីអាស៊ានអូស្ត្រាលីនូវែលសេឡង់ (ASEAN Australia New Zealand Free Trade Area Competition Committee) ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program) (‘CLIP’)។

## 2. តើសេដ្ឋកិច្ចជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់ក្នុងច្បាប់ប្រកួតប្រជែង ?

2.1 សេដ្ឋកិច្ចអាចត្រូវបានកំណត់ថាជា “វិទ្យាសាស្ត្រសង្គមទាក់ទងនឹងផលិតកម្ម ការចែកចាយ និងការប្រើប្រាស់ទំនិញ និងសេវាកម្ម”។ សេដ្ឋកិច្ចត្រូវបានគេចាត់ទុកថាជាវិទ្យាសាស្ត្រសង្គម ពីព្រោះវាអនុវត្តវិធីសាស្ត្រវិទ្យាសាស្ត្រដើម្បីសិក្សាពីសង្គម និងទំនាក់ទំនងសង្គម។ សេដ្ឋកិច្ចគឺជាឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់វាយតម្លៃផលប៉ះពាល់នៃការប្រព្រឹត្ត និងការរៀបចំនៅលើទីផ្សារ។

2.2 ការប្រកួតប្រជែងគឺជាគំនិតសេដ្ឋកិច្ច ដែលកំណត់លក្ខណៈដំណើរការទីផ្សារនៃការប្រជែងគ្នារវាងអ្នកលក់ដើម្បីបង្កើនប្រាក់ចំណេញរបស់ខ្លួន ដោយផ្តល់ជូនអ្នកទិញនូវការរួមបញ្ចូលគ្នានូវតម្លៃ គុណភាព និងសេវាកម្មល្អ ជាងការរួមផ្សំគ្នាដែលផ្តល់ដោយអ្នកប្រកួតប្រជែង។

2.3 ការដាក់ឱ្យអនុវត្តច្បាប់ប្រកួតប្រជែងផ្តល់ជូនទីផ្សារនូវ “ច្បាប់ល្បែង” ដែលការពារដល់ដំណើរការប្រកួតដោយខ្លួនវា ជាជាងការពារគូប្រកួតប្រជែងនៅក្នុងទីផ្សារ។ តាមរបៀបនេះ ការស្វែងរកការប្រកួតប្រជែងដោយស្មើភាព ឬប្រសិទ្ធភាព អាចចូលរួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពសេដ្ឋកិច្ច ប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។

2.4 សុខុមាលភាពគឺជាគំនិតស្តង់ដារមួយដែលត្រូវបានប្រើប្រាស់នៅក្នុងសេដ្ឋកិច្ច ដែលរួមបញ្ចូលសុខុមាលភាព (ឬអតិរេក) នៃក្រុមផ្សេងៗគ្នានៅក្នុងសេដ្ឋកិច្ច។ នៅក្នុងឧស្សាហកម្មមួយ សុខុមាលភាពអាចធ្វើការវាស់វែងដោយអតិរេកសរុប ដែលជាផលបូកនៃអតិរេកអតិថិជន (ភាពខុសគ្នារវាងអ្វីដែលអតិថិជនទាំងអស់ចង់ចំណាយសម្រាប់ផលិតផលមួយ និងតម្លៃពិតប្រាកដដែលពួកគេត្រូវចំណាយលើផលិតផលនោះ) និងអតិរេកអ្នកផលិត (ផលបូកនៃប្រាក់ចំណេញទាំងអស់ដែលអ្នកផលិតទទួលបាននៅក្នុងឧស្សាហកម្ម)។ វិធានការវាស់វែងនៃសុខុមាលភាពបែបនេះ គឺជាគំនិតស្តង់ដារក្នុងការវាយតម្លៃផលប៉ះពាល់នៃការប្រព្រឹត្ត និងការរៀបចំនៅលើទីផ្សារ។

2.5 នៅក្នុងបរិបទនៃច្បាប់ប្រកួតប្រជែង សេដ្ឋកិច្ចផ្តល់នូវក្របខ័ណ្ឌយ៉ាងម៉ត់ចត់សម្រាប់វិភាគទីផ្សារ និងឥទ្ធិពលនៃការប្រព្រឹត្តលើទីផ្សាររួមមាន (ផលប៉ះពាល់នៃ) ការប្រព្រឹត្តឯកតោភាគី ឬដែលមានការសម្របសម្រួលរបស់អ្នកចូលរួមទីផ្សារ (ផលប៉ះពាល់នៃការប្រកួតប្រជែង)។ ការវិភាគសេដ្ឋកិច្ចក៏អាចជាឧបករណ៍មានប្រយោជន៍ផងដែរក្នុងការកំណត់ និងវាយតម្លៃអង្គហេតុពាក់ព័ន្ធក្នុងករណីប្រកួតប្រជែង។ នៅជុំវិញពិភពលោក ភស្តុតាងសេដ្ឋកិច្ច ជាញឹកញាប់ត្រូវបានផ្តល់ឱ្យដោយអ្នកជំនាញសេដ្ឋកិច្ចក្នុងនាមគូភាគីនៅក្នុងករណីច្បាប់ប្រកួតប្រជែង។

2.6 ភស្តុតាងសេដ្ឋកិច្ចអាចជួយដល់តុលាការ ដោយពន្យល់ និងអនុវត្តគំនិតសេដ្ឋកិច្ចដែលអាចត្រូវបានបង្កប់នៅក្នុងច្បាប់ប្រកួតប្រជែងដូចជា៖

a. ការប្រកួតប្រជែង ពោលគឺការប្រជែងគ្នាទៅលើតម្លៃ គុណភាព សេវាកម្ម និងអថេរផ្សេងៗទៀតនៃតម្លៃ ជូនអ្នកប្រើប្រាស់ដើម្បីសម្រេចគោលបំណងអាជីវកម្ម ដូចជាការរកប្រាក់ចំណេញឱ្យបានច្រើនបំផុត។

b. សុខុមាលភាព រួមទាំងតម្លៃតាមការចូលចិត្ត សុខុមាលភាព និងចំណូលចិត្ត-ការពេញចិត្ត និង

c. ប្រសិទ្ធភាព គឺប្រសិទ្ធភាពមិនប្រែប្រួល (កម្រិតប្រសិទ្ធភាពនៅពេលណាមួយ ដោយផ្តោតលើផលិតផល ដំណើរការ ឬសមត្ថភាពដែលមានស្រាប់) និងប្រសិទ្ធភាពស្វាហាប់ (កម្រិតប្រសិទ្ធភាពតាមពេលកន្លងទៅ នៅពេលការផ្លាស់ប្តូរនេះ ឆ្លងកាត់ការបញ្ចូលរបៀបថ្មី ដែលនាំឱ្យមានផលិតផលថ្មី ដំណើរការ ឬសមត្ថភាពប្រសើរជាង)។ ប្រសិទ្ធភាពមិនប្រែប្រួលទាំងពីរប្រភេទនេះ គឺការបែងចែកធនធានដែលមាន ដល់តម្លៃខ្ពស់បំផុតរបស់ខ្លួន (ប្រសិទ្ធភាពបែងចែក) និងការបង្កើនលទ្ធផលពីធនធានដែលមានឱ្យបានច្រើនបំផុតនៅក្នុងតម្លៃទាបបំផុត (ប្រសិទ្ធភាពផលិតភាព)។

2.7 ការប្រកួតប្រជែងអាចលើកកម្ពស់ទាំងសុខុមាលភាព និងប្រសិទ្ធភាព តាមរយៈការបង្កើនតម្លៃ និងលើកទឹកចិត្តដល់ការបែងចែក និងការប្រើប្រាស់ធនធាន។ គំនិតសេដ្ឋកិច្ចទាំងនេះ ជាទូទៅគាំទ្រ និងជូនដំណឹងអំពីគោលបំណងនៃច្បាប់ប្រកួតប្រជែង។

## 3. ន័យនៃសេដ្ឋកិច្ច និងគំនិតសម្រាប់វាយតម្លៃការប្រកួតប្រជែង

3.1 នៅក្នុងទីផ្សារមានអ្នកទិញ និងអ្នកលក់ដែលធ្វើប្រតិបត្តិការទំនិញ និងសេវាកម្ម។ ទីផ្សារគឺជាទីលានប្រជែងគ្នា ឬទីលានសក្តានុពលនៃការប្រជែងគ្នារវាងអ្នកលក់ និងអ្នកលក់ដើម្បីលក់ផលិតផល ឬសេវាកម្មរបស់ខ្លួន។ ប្រសិនបើអ្នកលក់ដំឡើងតម្លៃ ( ទាក់ទងនឹងថ្លៃដើម ) នៃផលិតផល ឬសេវាកម្ម ប្រាក់ចំណេញសម្រាប់រាល់គ្រឿងដែលបានលក់នឹងកើនឡើង ក៏ប៉ុន្តែការលក់ទៅឱ្យអតិថិជនជាក់លាក់អាចនឹងបាត់បង់ ប្រសិនបើពួកគេមិនមានបំណងក្នុងការទិញផលិតផល ឬសេវាកម្មនោះក្នុងតម្លៃដែលបានដំឡើង ហើយបែរជាប្តូរទៅអ្នកលក់ផលិតផល ឬសេវាកម្មផ្សេងទៀត។

3.2 ការអនុវត្តនៃការបង្កើតទីផ្សារពាក់ព័ន្ធ ដែលគេហៅថានិយមន័យទីផ្សារ ផ្តល់នូវក្របខ័ណ្ឌវិភាគសម្រាប់ការសាកសួរចុងក្រោយថាតើការប្រព្រឹត្ត ឬប្រតិបត្តិការជាក់លាក់ណាមួយ ទំនងជាបង្កើតផលប៉ះពាល់ប្រឆាំងនឹងការប្រកួតប្រជែងដែរឬទេ។

3.3 ទីផ្សារអាចត្រូវបានកំណត់ថាមានជាប់ទាក់ទងនឹងផលិតផល និងវិមាត្រភូមិសាស្ត្រ រួមទាំងការពិចារណាលើការជំនួសផ្នែកសេដ្ឋកិច្ចមានក្នុងការផ្គត់ផ្គង់ និងតម្រូវការ។ វិមាត្រផលិតផល កំណត់ផលិតផលប្រកួតប្រជែងខុសគ្នាដែលគួរត្រូវបានគេចាត់ទុកថាមាននៅក្នុងទីផ្សារដូចគ្នា។ ឧទាហរណ៍ ទីប្រជុំជនមួយអាចមានហាងកីឡាតែមួយប៉ុណ្ណោះ ក៏ប៉ុន្តែនេះទំនងជាមិនមានភាពផ្តាច់មុខទេ ពីព្រោះប្រសិនបើហាងនេះដំឡើងថ្លៃរបស់ខ្លួន នោះអតិថិជនអាចប្តូរទៅបើហ្គើរ ឬហាងកីឡារបស់ទីក្រុងជិតខាងអាចពង្រីកតំបន់ចែកចាយរបស់ខ្លួន។ ប្រសិនបើការជំនួសបើហ្គើរ និង/ឬអ្នកលក់កីឡានៅតាមទីប្រជុំជនផ្សេងទៀត រារាំងម្ចាស់ហាងកីឡាពីការដំឡើងថ្លៃគួរឱ្យកត់សម្គាល់ ផលិតផល ហើយអ្នកលក់ទាំងនោះនឹងត្រូវដាក់បញ្ចូលទៅក្នុងទីផ្សារ ដែលគេហៅថាទីផ្សារពាក់ព័ន្ធ។

3.4 អំណាចទីផ្សារ គឺជាគោលគំនិតស្នូលមួយទៀតនៅក្នុងច្បាប់ប្រកួតប្រជែង និងផ្នែកសេដ្ឋកិច្ច។ ជាទូទៅ អំណាចទីផ្សារត្រូវបានកំណត់ថាជាសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទ្រទ្រង់តម្លៃពីលើ ឬកម្រិតគុណភាពពីក្រោមកម្រិតប្រកួតប្រជែង។ អត្ថប្រយោជន៍នៃអំណាចទីផ្សារ ផ្តល់នូវការលើកទឹកចិត្តដ៏រឹងមាំសម្រាប់ក្រុមហ៊ុនដើម្បីប្រកួតប្រជែងទទួលបានវា។ អំណាចទីផ្សារអាចទទួលបាន ថែរក្សា និងប្រើប្រាស់ដោយមិនបំពានលើច្បាប់ប្រកួតប្រជែង។ ច្បាប់ប្រកួតប្រជែង ជាទូទៅមានជាប់ពាក់ព័ន្ធតែនៅពេលដែលអំណាចទីផ្សារត្រូវបានទទួល រក្សា និង/ឬត្រូវបានប្រើក្នុងវិធីប្រឆាំងនឹងការប្រកួតប្រជែងប៉ុណ្ណោះ។

3.5 កម្រិតនៃអំណាចទីផ្សាររបស់ក្រុមហ៊ុន មិនងាយស្រួលនៅក្នុងការវាស់វែងដោយគ្មានភាពលម្អៀងទេ។ ចំណែកទីផ្សារ ជាញឹកញាប់មានភាពងាយស្រួលក្នុងការវាស់វែង ហេតុដូច្នេះហើយ ពេលខ្លះត្រូវបានប្រើជាសូចនាករ ឬការផ្តល់សិទ្ធិសម្រាប់អំណាចទីផ្សារ។ ទោះយ៉ាងណាក៏ដោយ គួរយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រនេះ ដោយហេតុថា ចំណែកទីផ្សារអាចផ្តល់ជារូបភាពមិនពេញលេញ ឬបណ្តោះអាសន្នតែប៉ុណ្ណោះ អំពីអំណាចទីផ្សាររបស់ក្រុមហ៊ុន។ កត្តាពាក់ព័ន្ធផ្សេងទៀត រួមមាន៖

a. ឧបសគ្គចំពោះការចូល និង/ឬការពង្រីក ពោលគឺភាពងាយស្រួលដែលដៃគូប្រកួតប្រជែងថ្មីអាចចូល ឬគូប្រជែងដែលមានស្រាប់អាចពង្រីកចូលទៅក្នុងទីផ្សារ ប្រសិនបើតម្លៃនៅក្នុងទីផ្សារកើនឡើងខ្ពស់ជាងកម្រិតប្រកួតប្រជែង។ លទ្ធភាពនៃក្រុមហ៊ុនថ្មីចូលក្នុងទីផ្សារនេះ ឬការពង្រីកគូប្រជែងបច្ចុប្បន្នកំពុងរារាំង ឬធ្វើឱ្យមានការលំបាកសម្រាប់ក្រុមហ៊ុនក្នុងការគិតថ្លៃខ្ពស់ជាងកម្រិតប្រកួតប្រជែង។ ហេតុដូច្នេះហើយ ប្រសិនបើឧបសគ្គចំពោះការចូល និងការពង្រីកមានកម្រិតទាប នោះក្រុម

ហ៊ុនដែលកំពុងកាន់អំណាចនឹងមិនអាចអនុវត្តអំណាចទីផ្សារប្រកបដោយនិរន្តរភាពបានទេ បើទោះបីជាពួកគេមានចំណែកទីផ្សារធំក៏ដោយ។

b. អំណាចជំទាស់របស់ (អ្នកទិញ) គឺជាកម្លាំងចរចាររបស់អ្នកទិញក្នុងការចរចារជាមួយអ្នកលក់។ សមត្ថភាពរបស់អ្នកទិញក្នុងការចរចាជាមួយអ្នកលក់ ឧទាហរណ៍ ដោយសារទំហំរបស់អ្នកទិញ សារៈសំខាន់ពាណិជ្ជកម្មរបស់អ្នកលក់ ឬសមត្ថភាពផ្គត់ផ្គង់ខ្លួនឯង ឬឧបត្ថម្ភការចូលថ្មីរបស់អ្នកលក់ផ្សេងទៀត ដើរតួជាកម្លាំងដាក់វិន័យ និងលើកកម្ពស់ឥរិយាបថប្រកួតប្រជែងនៅខាងអ្នកលក់។

c. បទប្បញ្ញត្តិសេដ្ឋកិច្ចអាចជាកត្តាពាក់ព័ន្ធនៅក្នុងវិស័យ ជាឧទាហរណ៍ តម្លៃ និង/ឬកម្រិតគុណភាពស្ថិតនៅក្រោមការគ្រប់គ្រងដោយនិយតកររដ្ឋាភិបាល។ តក្តានេះ អាចកំណត់វិសាលភាពដែលក្រុមហ៊ុនអាចទាញយកផលចំណេញពីទីផ្សាររបស់ខ្លួន និង

d. ចរិតលក្ខណៈរបស់ក្រុមហ៊ុន និងទីផ្សារជាក់លាក់ រួមទាំងការទាក់ទងនឹងរចនាសម្ព័ន្ធទីផ្សារសមស្របផងដែរ។

## 4. គំរូសេដ្ឋកិច្ចសម្រាប់ការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង

4.1 អ្នកសេដ្ឋកិច្ចតែងតែប្រើគំរូសេដ្ឋកិច្ច ដើម្បីពន្យល់អំពីពិភពពិតប្រាកដតាមរយៈការធ្វើឱ្យសាមញ្ញ និងការធ្វើអរូបិយកម្មមួយចំនួន។ មានគំរូទីផ្សារសេដ្ឋកិច្ចផ្សេងៗគ្នាដែលអាចយកប្រើ សម្រាប់ការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង។ គំរូដែលសមរម្យនឹងពឹងផ្អែកលើអង្គហេតុនៃករណីជាក់លាក់។ គំរូទីផ្សារសេដ្ឋកិច្ចមូលដ្ឋានចំនួនបួន ដែលខុសគ្នាទាក់ទងនឹងចំនួននៃការប្រកួតប្រជែងដែលកើតឡើងនៅក្នុងទីផ្សារ មានពិពណ៌នាលម្អិតបន្ថែមទៀតខាងក្រោម។

4.2 គំរូនៃការប្រកួតប្រជែងដ៏ល្អឥតខ្ចោះ (សម្មតិកម្ម) ពិពណ៌នាអំពីរចនាសម្ពន្ធ័ទីផ្សារមួយ ដែលការប្រកួតប្រជែងស្ថិតនៅក្នុងកម្រិតខ្ពស់បំផុតដែលអាចធ្វើទៅបាន។ វាត្រូវបានកំណត់ដោយលក្ខខណ្ឌទីផ្សារឧត្តមគតិជាច្រើន ឧទាហរណ៍ រួមមានព័ត៌មានល្អឥតខ្ចោះអាចរកបានសម្រាប់អតិថិជន និងអ្នកផលិតទាំងអស់ មិនមានឧបសគ្គចូល ឬចេញ ហើយមានអ្នកទិញ និងអ្នកលក់ទំនិញ ឬសេវាកម្មដែលមានលក្ខណៈដូចគ្នា ដែលទាំងអស់គ្នាធ្វើសកម្មភាពសមហេតុផលល្អឥតខ្ចោះ។ នៅក្នុងគំរូនេះ មិនមានក្រុមហ៊ុនណាមួយដែលមានអំណាចទីផ្សារដ៏ខ្លាំង ឬសមត្ថភាពក្នុងការដាក់ឥទ្ធិពលលើតម្លៃទេ។ គំរូនេះបង្កើតលទ្ធផលល្អប្រសើរ ទាក់ទងនឹងសុខុមាលភាព និងប្រសិទ្ធភាព ហើយជាគោលសម្រាប់ការវាយតម្លៃផលប៉ះពាល់នៃការប្រព្រឹត្តនៅក្នុងរចនាសម្ព័ន្ធ ទីផ្សារដែលមានការប្រកួតប្រជែងមិនល្អឥតខ្ចោះ។

4.3 គំរូនៃការប្រកួតប្រជែងផ្តាច់មុខ ក៏ទទួលបានអ្នកទិញ និងអ្នកលក់មួយចំនួនធំដែរ ដែលអាចចូល និងចេញបានយ៉ាងងាយស្រួល ក៏ប៉ុន្តែផលិតផលក្នុងគំរូនេះមិនមានលក្ខណៈដូចគ្នាទេ។ ភាពខុសគ្នានៃផលិតផល អនុញ្ញាតឱ្យក្រុមហ៊ុនអនុវត្តអំណាចទីផ្សារមួយចំនួន និងធ្វើការសម្រេចចិត្តតម្លៃឯករាជ្យ ដែលអាចនាំឱ្យឡើងតម្លៃខ្ពស់ ឬសមត្ថភាពមិនដំណើរការ បើប្រៀបធៀបនឹងស្ថានភាពនៃការប្រកួតប្រជែងដ៏ល្អឥតខ្ចោះ។

4.4 នៅក្នុងគំរូពហុធិភាព ដែលមានតែអ្នកលក់តែពីរបីនាក់ដែលមានទំហំធំប៉ុណ្ណោះ។ ក្រុមហ៊ុនទាំងនេះដឹង ហើយគិតពីសកម្មភាព និងប្រតិកម្មរំពឹងទុករបស់ខ្លួនម្នាក់ៗ នៅពេលធ្វើការកំណត់តម្លៃ និងការសម្រេចចិត្តប្រកួតប្រជែងផ្សេងទៀត។ ក្រុមហ៊ុននៅក្នុងទីផ្សារពហុធិភាព គឺពឹងផ្អែកគ្នាទៅវិញទៅមក។ នៅក្នុងស្ថានភាពពហុធិភាព កម្រិតនៃការប្រកួតប្រជែងអាចមានភាពខុសគ្នាច្រើនអាស្រ័យសំខាន់លើកាលៈទេសៈជាក់លាក់នៃទីផ្សារ។ អ្នកលក់អាចប្រកួតប្រជែងខ្លាំង ឬក្រុមហ៊ុននីមួយៗអាចមាន

អំណាចទីផ្សារយ៉ាងច្រើន និងមានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងគ្នាដោយស៊ីសង្វាក់គ្នាយ៉ាងស្វាត់ស្មៀម ដោយរួមបញ្ចូលគ្នារវាងអំណាចទីផ្សារដើម្បីជំរុញតម្លៃឱ្យឡើងថ្លៃ និងប្រាក់ចំណេញរហូតដល់មានការបំផ្លាញដល់ប្រសិទ្ធភាព និងសុខុមាលភាព (និងអ្នកប្រើប្រាស់)។ ជាលទ្ធផល លទ្ធផលពហុធិភាព អាចមើលទៅស្រដៀងគ្នានឹងការប្រកួតប្រជែងផ្ដាច់មុខដែរ។

4.5 នៅក្នុងគំរូផ្ដាច់មុខ មានតែអ្នកលក់ម្នាក់ប៉ុណ្ណោះដែលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើទីផ្សារទាំងមូល។ អ្នកលក់នោះអាចប្រើអំណាចទីផ្សារផ្ដាច់មុខរបស់ខ្លួនដើម្បីរក្សាតម្លៃ និងប្រាក់ចំណេញលើសពីកម្រិតដែលមានប្រសិទ្ធិភាព ហើយដើម្បីផលិតតិចជាងចំនួនដ៏ប្រសើរបំផុត។ ច្បាប់ប្រកួតប្រជែង ជាទូទៅមិនហាមឃាត់ភាពផ្ដាច់មុខដោយខ្លួនឯងនោះទេ គឺហាមឃាត់តែការប្រើប្រាស់តួនាទីគ្របដណ្ដប់ដើម្បីធ្វើឱ្យអន្តរាយដល់ការប្រកួតប្រជែងប៉ុណ្ណោះ។ ច្បាប់ប្រកួតប្រជែងក៏អាចរារាំងការធ្វើអាជីវកម្មផ្ដាច់មុខពីការបង្កើតលទ្ធផលនៃប្រតិបត្តិការ (ការរួមបញ្ចូលគ្នា ឬការទិញយក) ឬការប្រព្រឹត្តប្រឆាំងនឹងការប្រកួតប្រជែងផងដែរ។

4.6 ច្បាប់ប្រកួតប្រជែងផ្ដោតសំខាន់លើការប្រព្រឹត្តរបស់ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងទីផ្សារពហុធិភាព ឬទីផ្សារផ្ដាច់មុខ។ នេះគឺដោយសារតែក្រុមហ៊ុនដែលប្រតិបត្តិការនៅក្នុងទីផ្សារប្រភេទនេះ មានសក្ដានុពលខ្ពស់បំផុតក្នុងការប្រើប្រាស់អំណាចទីផ្សាររបស់ខ្លួនដើម្បីធ្វើឱ្យអន្តរាយដល់ការប្រកួតប្រជែង។

## 5. ការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង

5.1 ការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង ជាទូទៅមិនចាំបាច់នៅក្នុងករណីកាតែល (ក្រុមហ៊ុនអន្តរជាតិផ្ដាច់មុខ) ទេ ពីព្រោះកិច្ចព្រមព្រៀងកាតែល ជាទូទៅត្រូវបានចាត់ទុកថាជាការរំលោភបំពានដ៏ធ្ងន់ធ្ងរបំផុតទៅលើច្បាប់ប្រកួតប្រជែង ហើយជាទូទៅត្រូវបានហាមឃាត់ដោយមិនចាំបាច់គិតពីផលប៉ះពាល់ជាក់លាក់របស់កាតែលនោះទេ។ កាតែលស្ទើរតែធ្វើឱ្យអតិថិជនរងគ្រោះជានិច្ចដោយការដំឡើងថ្លៃ និងការរឹតត្បិតការផ្គត់ផ្គង់ ដូច្នេះធ្វើឱ្យទំនិញ និងសេវាកម្មមិនអាចមានទាំងស្រុង សម្រាប់អ្នកទិញមួយចំនួន និងធ្វើឱ្យមានតម្លៃឡើងខ្ពស់ដែលមិនចាំបាច់សម្រាប់អ្នកទិញផ្សេងទៀត។

5.2 ផ្ទុយទៅវិញ ការវាយតម្លៃអំពីផលប៉ះពាល់នៃការប្រកួតប្រជែង ជាទូទៅចាំបាច់ត្រូវមាននៅក្នុងការពិចារណាលើទម្រង់នៃការប្រព្រឹត្ត ឬការរៀបចំផ្សេងទៀត (មិនមែនកាតែល) ជាពិសេស ក្នុងការពិចារណាលើការអនុម័តលើការដាក់បញ្ចូលគ្នា និងការទិញយក ក្នុងការវាយតម្លៃកិច្ចព្រមព្រៀងនានាដែលអាចកាត់បន្ថយខ្លាំងនូវការប្រកួតប្រជែង និងក្នុងការវាយតម្លៃករណីការរំលោភបំពានលើតួនាទីគ្របដណ្ដប់ ដែលក្នុងនោះ ការរកឃើញនូវទទួលខុសត្រូវ ជាធម្មតាតម្រូវឱ្យមានទាំងកម្រិតដ៏ធំនៃអំណាចទីផ្សារ ព្រមទាំងគោលដៅ ឬផលប្រឆាំងនឹងការប្រកួតប្រជែង។

5.3 ក្នុងការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង ជាទូទៅអ្នកសេដ្ឋកិច្ចផ្ដោតលើស្ថានភាពនៃការប្រកួតប្រជែងនៅក្នុងទីផ្សារទាំងមូល ជាជាងឥទ្ធិពលនៃការប្រព្រឹត្តទៅលើគូប្រកួតប្រជែងជាក់លាក់។ ការពាក់ព័ន្ធជាពិសេសកំពុងពិចារណាថាតើការប្រព្រឹត្តនោះបង្កើត បង្កើន ឬរក្សាអំណាចទីផ្សារនៅលើទីផ្សារដែរឬទេ ឧទាហរណ៍ បង្កើនឧបសគ្គចំពោះការចូល និងការពង្រីក ឬមិនរាប់បញ្ចូលគូប្រជែងពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារ។ មានតេស្តជាច្រើនដែលអាចមានប្រយោជន៍ក្នុងការវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង ដែលរួមមាន៖

a. ការធ្វើតេស្ត ‘ដោយមាន ឬគ្មាន’ ដែលប្រៀបធៀបស្ថានភាពដែលអាចមានការប្រកួតប្រជែងនៅក្នុងទីផ្សារ ជាមួយនឹងការប្រព្រឹត្តដែលបានធ្វើតេស្ត ទៅនឹងស្ថានភាពនៃការប្រកួតប្រជែងនៅក្នុងទីផ្សារនោះ ដោយគ្មានការប្រព្រឹត្តដែលបានធ្វើតេស្ត។

b. ការធ្វើតេស្ត ‘ការប្រើប្រាស់ធនធានប្រកបដោយគ្មានការប្រុងប្រយ័ត្ន និងគ្មានប្រសិទ្ធភាព’ ដែលចោទសួរថាតើការប្រព្រឹត្តដែល

បានធ្វើតេស្ត នឹងនៅតែមានការប្រើប្រាស់ធនធានប្រកបដោយគ្មានការប្រុងប្រយ័ត្ន និងគ្មានប្រសិទ្ធភាពដែរឬទេ ដោយគ្មានគោលបំណង ឬផលប៉ះពាល់ការប្រឆាំងនឹងការប្រកួតប្រជែងណាមួយ និង

c. ការធ្វើតេស្ត ‘ជាដៃគូប្រកួតប្រជែងដែលមានប្រសិទ្ធិភាព’ ដែលចាត់ទុកថាការប្រព្រឹត្តដែលបានធ្វើតេស្ត មុខជាមិនរាប់បញ្ចូលទាំងគូប្រកួតប្រជែងដែលយ៉ាងហោចណាស់មានប្រសិទ្ធភាព ដូចក្រុមហ៊ុនដែលចូលរួមក្នុងការប្រព្រឹត្តដែលបានធ្វើតេស្តក្នុងលំនាំមួយដែលធ្វើឱ្យខូចខាតដល់ការប្រកួតប្រជែងនៅលើទីផ្សារទាំងមូល។

5.4 ការអនុវត្តនៃការធ្វើតេស្តខាងលើដើម្បីវាយតម្លៃពីផលប៉ះពាល់នៃការប្រកួតប្រជែងគឺមិនដែលស្រួលឡើយ ហើយអាចទាមទារឱ្យមានការវិភាគសេដ្ឋកិច្ច និងភស្តុតាងអ្នកជំនាញ។ ឧទាហរណ៍ ក្នុងការអនុវត្តការធ្វើតេស្ត ‘ដោយមាន ឬគ្មាន’ ចំពោះការអនុម័តការរួមបញ្ចូលគ្នា វាមិនអាចធ្វើទៅរួចទេក្នុងការសន្មតថាស្ថានភាពប្រកួតប្រជែងបច្ចុប្បន្ននៅក្នុងទីផ្សារនឹងត្រូវបានរក្សាទុក ‘ដោយគ្មាន’ ការរួមបញ្ចូលគ្នា។ នៅក្នុងការអនុម័តការរួមបញ្ចូលគ្នារបស់ប្រទេសអូស្ត្រាលីនាពេលថ្មីៗនេះ ពាក់ព័ន្ធនឹងសេវាកម្មដឹកទំនិញតាមសមុទ្រ វាត្រូវបានគេរកឃើញថាបើគ្មានការរួមបញ្ចូលគ្នាទេនោះ គោលដៅរបស់សេវាកម្មដឹកជញ្ជូនទំនិញដែលមានស្រាប់នឹងត្រូវបញ្ឈប់ ហើយអ្នកទិញអនាគតក្នុងករណីណាក៏ដោយ មុខជាអាចជានាការពាររាល់កិច្ចសន្យាអតិថិជន ដែលធ្វើឱ្យសេវាកម្មដឹកជញ្ជូនអាចបិតបេរបាន។ ក្នុងកាលៈទេសៈទាំងនេះ ការរួមបញ្ចូលគ្នាត្រូវបានអនុម័តលើលក្ខខណ្ឌ ការប្តេជ្ញាចិត្ត និងការសន្យាដើម្បីកាត់បន្ថយផលប៉ះពាល់ប្រឆាំងនឹងការប្រកួតប្រជែង។

5.5 វាចាំបាច់ក្នុងការពិចារណាលើឥទ្ធិពលនៃការប្រកួតប្រជែង ដោយចងចាំពីច្បាប់ដែលត្រូវអនុវត្ត និងគោលបំណងនៃច្បាប់នោះ។ ការវិភាគ និងភ័ស្តុតាងសេដ្ឋកិច្ច អាចជួយក្នុងការបង្ហាញពីផលប៉ះពាល់លើការប្រកួតប្រជែង និងលទ្ធផលទីផ្សារនៃការប្រព្រឹត្ត ឬការរៀបចំនានាដែលកំពុងត្រូវពិចារណា។ ទន្ទឹមគ្នានឹងពេលនេះដែរ វាជាការសំខាន់ណាស់ដែលមិនត្រូវអនុញ្ញាតឱ្យគំនិតបច្ចេកទេសសេដ្ឋកិច្ច ដាក់ជំនួសភាសានៃច្បាប់ឡើយ។

## 6. ប្រភពព័ត៌មានពាក់ព័ន្ធ

6.1 ធនធានខាងក្រោម ផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងនឹងសេដ្ឋកិច្ចនៅក្នុងបរិបទនៃច្បាប់ប្រកួតប្រជែង។ ឯកសារនេះប្រើជាឯកសារយោងទូទៅដ៏មានប្រយោជន៍ សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន៖

a. OECD *អនុសាសន៍របស់ក្រុមប្រឹក្សា OECD ទាក់ទងនឹងសកម្មភាពដែលមានប្រសិទ្ធិភាពប្រឆាំងនឹងក្រុមចលនាការតែល* ឆ្នាំ១៩៩៨

b. Massimo Motta *គោលនយោបាយប្រកួតប្រជែង ទ្រឹស្តី និងការអនុវត្ត* ឆ្នាំ២០០៤

c. គោលនយោបាយតុមូលរបស់ OECD ស្តីពីការប្រកួតប្រជែង (OECD Competition Policy Roundtables) ឧបសគ្គក្នុងការចូល ឆ្នាំ២០០៥

d. OECD Competition Policy Roundtables *ការកំណត់បរិមាណនៃការបង្កគ្រោះថ្នាក់ដល់ការប្រកួតប្រជែងដោយតុលាការជាតិ និងភ្នាក់ងារប្រកួតប្រជែង* ឆ្នាំ២០១១

e. OECD Competition Policy Roundtables និយមន័យទីផ្សារ ឆ្នាំ២០១២

*f.* OECD *សទ្ទានុក្រមនៃពាក្យស្ថិតិ*

g. បណ្តាញការប្រកួតប្រជែងអន្តរជាតិ (International Competition Network) *ការបណ្តុះបណ្តាលលើតម្រូវការ* រួមមានគំរូស្តីពី*អំណាចទីផ្សារ* *ផលប៉ះពាល់នៃការប្រកួតប្រជែង* និង *សេដ្ឋកិច្ចនៃតួនាទីគ្រប់ដណ្តប់*

# សៀវភៅមូលដ្ឋានសម្រាប់ចៅក្រមអាស៊ានស្តីពីការប្រកួតប្រជែង

បង្កើតឡើងជាផ្នែកនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែងរបស់ AANZFTA
(AANZFTA Competition Law Implementation Program)

## *ភ័ស្តុតាងអ្នកជំនាញនៅក្នុងបរិបទនៃសំណុំរឿងច្បាប់ប្រកួតប្រជែង*

### 1. សេចក្តីផ្តើម

1.1 សៀវភៅមូលដ្ឋាននេះ មានគោលបំណងដើម្បី៖

a. ធ្វើជាឯកសារផ្អែកលើគោលការណ៍សម្រាប់ការប្រើប្រាស់ដោយសមាជិកតុលាការ ក្នុងរដ្ឋជាសមាជិកនីមួយៗរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (Association of Southeast Asian Nations) ('ASEAN')។

b. ផ្តល់នូវមគ្គុទេសក៍ជាក់ស្តែង និងផ្តល់ព័ត៌មានដល់ចៅក្រមដោយផ្តោតលើការប្រឈម និងបញ្ហាដែលជួបប្រទះនៅក្នុងការវាយតម្លៃភ័ស្តុតាងស្មុគស្មាញពីអ្នកជំនាញក្នុងពេលធ្វើការ និងពិនិត្យសេចក្តីសម្រេចនានាក្រោមច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន និង

c. ជួយក្នុងការអភិវឌ្ឍច្បាប់ប្រកួតប្រជែងពីមុន ដែលបង្កើនភាពច្បាស់លាស់ផ្នែកច្បាប់ លើកកម្ពស់ប្រសិទ្ធភាព និងជំរុញសង្គតិភាព និងភាពអាចព្យាករណ៍បាននៅក្នុងបណ្តារដ្ឋជាសមាជិកអាស៊ាន និងចុងក្រោយ ចូលរួមចំណែកក្នុងការកំណត់គោលនយោបាយការប្រកួតប្រជែងមានលក្ខណៈល្អប្រសើរ។

1.1 សៀវភៅមូលដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃភាពផ្សេងគ្នា និងដំណាក់កាលខុសៗគ្នានៃការរៀបចំច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ សៀវភៅនេះមិនមានបំណងផ្តល់ព័ត៌មានជាក់លាក់ទៅតាមប្រទេសនីមួយៗទេ។

1.2 សៀវភៅមូលដ្ឋាននេះត្រូវបានបង្កើតឡើងដោយចៅក្រមនៃតុលាការសហព័ន្ធអូស្ត្រាលី សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយ OECD។ នេះគឺជាសៀវភៅមួយនៅក្នុងចំណោមសៀវភៅមូលដ្ឋានស្តីពីច្បាប់ប្រកួតប្រជែងជាបន្តបន្ទាប់ ដែលត្រូវបានបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់គណៈកម្មការប្រកួតប្រជែងតំបន់ពាណិជ្ជកម្មសេរីអាស៊ានអូស្ត្រាលីនូវែលសេឡង់ (ASEAN Australia New Zealand Free Trade Area Competition Committee) ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program) ('CLIP')។

### 2. តួនាទីធម្មតានៃភ័ស្តុតាងអ្នកជំនាញក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង

2.1 នៅក្នុងយុត្តាធិការជាច្រើន រាប់បញ្ចូលទាំងក្នុងបណ្តាប្រទេសអាស៊ាន តុលាការប្រឈមមុខនឹងបញ្ហាច្បាប់ប្រកួតប្រជែង ជាចម្បងនៅក្នុងបរិបទនៃការពិនិត្យរបស់តុលាការ ទៅលើសេចក្តីសម្រេចដែលបានធ្វើឡើងដោយអាជ្ញាធរត្រួតពិនិត្យការប្រកួតប្រជែង។ មានការពិនិត្យរបស់តុលាការចំនួនពីរប្រភេទធំៗដែលតុលាការអាចនឹងត្រូវចូលរួម។ ប្រភេទនៃការពិនិត្យឡើងវិញទីមួយ គឺពាក់ព័ន្ធនឹងថាតើសេចក្តីសម្រេចនោះត្រឹមត្រូវឬអត់។ ចំណុចនេះអាចតម្រូវឱ្យមានការពិនិត្យភាពស្របច្បាប់នៃសកម្មភាពរបស់អាជ្ញាធរដោយផ្អែក

លើមូលដ្ឋានមានកំណត់ជាក់លាក់ ដែលជាធម្មតាគឺភាពផ្ទុយនឹងច្បាប់ ភាពមិនសមហេតុផល ឬនីតិវិធីមិនត្រឹមត្រូវនៃការប្រព្រឹត្តិដែលជំទាស់។ ការពិនិត្យឡើងវិញលើមូលដ្ឋានទាំងនោះ នៅតែអាចមានការពិនិត្យយ៉ាងលម្អិតអំពីអង្គហេតុ និងភ័ស្តុតាង ហើយនិងភាពសមស្របនៃសកម្មភាពដែលបានធ្វើឡើងលើមូលដ្ឋាននៃអង្គហេតុ និងភ័ស្តុតាងទាំងនោះ។ ការពិនិត្យរបស់តុលាការក៏អាចមានលើលក្ខណៈសម្បត្តិផងដែរ ពោលគឺលើខ្លឹមសារនៃសកម្មភាព ឬសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងការវាយតម្លៃពេញលេញឡើងវិញលើភាពត្រឹមត្រូវនៃសេចក្តីសម្រេចនោះ។ វិសាលភាពដែលការពិចារណាឡើងវិញនៃលក្ខណៈសម្បត្តិដែលអាចអនុញ្ញាតបាន គឺខុសគ្នាពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត។

2.2 ការពិនិត្យរបស់តុលាការទាំងពីរប្រភេទក៏ដូចជាករណីផ្សេងទៀតដែរ ដែលអាចពាក់ព័ន្ធនឹងបញ្ហាច្បាប់ប្រកួតប្រជែង អាចតម្រូវឱ្យតុលាការកំណត់ទីផ្សារពាក់ព័ន្ធ ឬវាយតម្លៃផលប៉ះពាល់នៃការប្រកួតប្រជែង។ ជាលទ្ធផល កត្តានេះតម្រូវឱ្យតុលាការប្រើប្រាស់សេដ្ឋកិច្ច និងគំនិតសេដ្ឋកិច្ច ក៏ដូចជាតម្រូវឱ្យប្រើប្រាស់ចំណេះដឹងខាងបច្ចេកទេស ឬឧស្សាហកម្ម ទោះបីជាមានការតម្រូវឱ្យមានការវិភាគភាពស្មុគស្មាញផ្សេងៗគ្នាក្តី អាស្រ័យលើរឿងក្តីនោះក៏ដោយ។ ចំណុចនេះប្រហែលជាមិនតម្រូវឱ្យមានក្នុងគ្រប់ករណីទេ។ គំនិតសេដ្ឋកិច្ចអាចជួយជូនដំណឹងអំពីការពិនិត្យបញ្ហាជាក់លាក់នៅក្នុងរឿងក្តីដែលបានផ្តល់ឱ្យ ហើយជួយបំភ្លឺលើសំណុំនៃអង្គហេតុដែលស្មុគស្មាញជាញឹកញាប់។ ឧទាហរណ៍ ច្បាប់ប្រកួតប្រជែងរួមបញ្ចូលទាំងគំនិតដូចជា "ទីផ្សារ", "ការរឹតត្បិតការប្រកួតប្រជែង", "ការរឹបអូសយកសិទ្ធិជាម្ចាស់", " ការរំលោភបំពានលើតួនាទីគ្របដណ្តប់" និងអ្វីផ្សេងទៀតដែលចៅក្រមមិនធ្លាប់ដឹងច្បាស់ក្នុងការដោះស្រាយប្រភេទរឿងក្តីផ្សេងទៀត។ គំនិតទាំងនេះមិនអាចបកស្រាយដោយគ្រាន់តែសម្លឹងមើលអត្ថន័យធម្មតានៃពាក្យនោះទេ ក៏ប៉ុន្តែតម្រូវឱ្យមានការយល់ដឹងអំពីសេដ្ឋកិច្ចដែលបង្កើតជាមូលដ្ឋាន និងផ្តល់ព័ត៌មានអំពីគំនិតទាំងនេះផងដែរ។ លើសពីនេះទៅទៀត គំនិតទាំងនេះអាចវិវឌ្ឍន៍ទៅតាមពេលវេលា ដែលការស្រាវជ្រាវខាងសេដ្ឋកិច្ចបង្កើនការយល់ដឹងបន្ថែមទៀតអំពីតួនាទីនៃការប្រកួតប្រជែងក្នុងការជួយឱ្យទីផ្សារដំណើរការ។

2.3 ហេតុដូច្នេះហើយទើបលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលនយោបាយ និងការអនុវត្តច្បាប់ប្រកួតប្រជែង ហើយនិងនៅក្នុងការបកស្រាយច្បាប់ប្រកួតប្រជែង ដូច្នេះចៅក្រមអាចទទួលបានជំនួយពីការពិចារណាលើគំនិត និងគោលការណ៍សេដ្ឋកិច្ចដែលពាក់ព័ន្ធ។

2.4 ចៅក្រមអាចទទួលបានអត្ថប្រយោជន៍ពីការពន្យល់របស់អ្នកជំនាញមិនលម្អៀង និងការបកស្រាយអំពីគំនិតសេដ្ឋកិច្ច និងជំនាញឧស្សាហកម្ម ពាក់ព័ន្ធនឹងសំណួរជាក់លាក់ ឬបញ្ហាដែលកើតឡើងនៅក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង។

2.5 តួនាទីសំខាន់របស់សាក្សីជំនាញក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង គឺដើម្បីជួយដល់តុលាការដោយផ្តល់នូវគោលបំណង និងមតិមិនលម្អៀងទាក់ទងនឹងសំណួរ ឬបញ្ហាដែលស្ថិតនៅក្នុងវិស័យនៃជំនាញការចេះដឹងរបស់អ្នកជំនាញ។ តួនាទីរបស់តុលាការ គឺវាយតម្លៃភ័ស្តុតាងអ្នកជំនាញ និងដើម្បីធ្វើការសន្និដ្ឋានដោយខ្លួនឯងលើសំណួរនៃអង្គហេតុ និងអង្គច្បាប់។ ទោះយ៉ាងណាក៏ដោយ ការទទួលខុសត្រូវច្បាស់លាស់របស់តុលាការ ខុសគ្នាពីយុត្តាធិការ ទៅយុត្តាធិការ ហើយមានភាពខុសគ្នាក្នុងការប្រើប្រាស់អ្នកជំនាញ និងទំនាក់ទំនងរវាងចៅក្រម និងអ្នកជំនាញពេញទូទាំងយុត្តាធិការ។ នៅក្នុងយុត្តាធិការនៃច្បាប់ទូទៅ (common law) និងច្បាប់រដ្ឋប្បវេណី ចៅក្រមជាអ្នកទទួលខុសត្រូវចុងក្រោយដើម្បីវាយតម្លៃភ័ស្តុតាងអ្នកជំនាញ។ ភាពខុសគ្នាសំខាន់ៗ ទាក់ទងនឹងរបៀបដែលភ័ស្តុតាងអ្នកជំនាញត្រូវបានណែនាំ និងភាពធំធេងនៃការត្រួតពិនិត្យដែលតុលាការមានលើការផលិតភ័ស្តុតាងអ្នកជំនាញ។ នៅក្នុងប្រព័ន្ធច្បាប់ទូទៅ វាគឺសម្រាប់ភាគីដែលត្រូវបង្ហាញ ហើយជំទាស់នឹងភ័ស្តុតាង ហើយតួនាទីរបស់ចៅក្រមនៅដំណាក់កាលនេះជាចម្បង គឺដើម្បីគ្រប់គ្រងនូវអ្វីដែលភ័ស្តុតាងដឹកនាំដោយភាគីអាចទទួលយកបាន។ ម៉្យាងវិញទៀត នៅក្នុងយុត្តាធិការនៃច្បាប់រដ្ឋប្បវេណី ជាទូទៅចៅក្រមធ្វើការសម្រេចថាតើភ័ស្តុតាងអ្នកជំនាញមួយណាដែលគួរបង្ហាញ និងជ្រើសរើសអ្នកជំនាញ។

2.6 នៅទូទាំងពិភពលោក តួនាទីរបស់សាក្សីជំនាញគឺមិនត្រូវដើរតួជាអ្នកគាំទ្រភាគីណាមួយឡើយ។ ដោយមិនគិតពីអ្នកណាដែលរក្សាសេវាកម្មរបស់ពួកគេ កាតព្វកិច្ចដែលសំខាន់ជាងគេរបស់សាក្សីជំនាញ គឺដើម្បីជួយដល់តុលាការ។

2.7 ភាពស្មុគស្មាញនៃភស្តុតាងសេដ្ឋកិច្ច និងការព្រួយបារម្ភអំពីភាពមិនលម្អៀងនៃសាក្សីជំនាញ បង្កើតឱ្យមានបញ្ហាប្រឈមទាក់ទងនឹងវិធីគ្រប់គ្រង និងវាយតម្លៃភស្តុតាងទាំងនោះ។ បញ្ហាប្រឈមទាំងនេះ បាននាំឱ្យមានការអភិវឌ្ឍនៃបច្ចេកទេសគ្រប់គ្រងករណីនៅទូទាំងដែនយុត្តាធិការជាច្រើន រួមទាំងវិធានស្តីពី៖

a. លក្ខណៈសម្បត្តិរបស់អ្នកជំនាញ

b. ភាពអាចទទួលយកបាននៃភស្តុតាងអ្នកជំនាញ

c. ការពិនិត្យភស្តុតាងអ្នកជំនាញ និង

d. ការតែងតាំងអ្នកជំនាញរួម ឬអ្នកជំនាញតែងតាំងដោយតុលាការ។

2.8 វាក៏បាននាំទៅដល់ការផ្តល់ឱ្យតុលាការនូវប្រភពជំនាញខាងសេដ្ឋកិច្ច និងការខិតខំដើម្បីអភិវឌ្ឍសមត្ថភាព និងជំនាញបច្ចេកទេសរបស់ចៅក្រមផងដែរ។

2.9 យុត្តាធិការផ្សេងគ្នាបានអនុវត្តវិធីសាស្ត្រផ្សេងៗគ្នា ក្នុងការគ្រប់គ្រងករណីនៃភស្តុតាងអ្នកជំនាញ។ សៀវភៅមូលដ្ឋាននេះ ពិភាក្សាអំពីការយល់ដឹងមួយចំនួន ដែលកើតឡើងភាគច្រើនពីបទពិសោធន៍របស់ចៅក្រមនៅប្រទេសអូស្ត្រាលីដែលអាចពាក់ព័ន្ធ សម្រាប់សមាជិកតុលាការនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។

2.10 ដោយសារតួនាទីរបស់សាក្សីជំនាញគឺដើម្បីជួយដល់តុលាការ ជាទូទៅនៅជុំវិញពិភព លោកតុលាការអាចបញ្ជាឱ្យតែងតាំងសាក្សីជំនាញឯករាជ្យតាមសំណើរបស់ខ្លួន។ នៅក្នុងប្រព័ន្ធមួយចំនួន មានតែអ្នកជំនាញដែលបានតែងតាំងដោយតុលាការប៉ុណ្ណោះដែលត្រូវបានអនុញ្ញាត ហើយវាមានសារសំខាន់ណាស់ដែលការតែងតាំងអ្នកជំនាញបែបដូចនេះគឺមិនលម្អៀង និងត្រូវមានតម្លាភាព។ ចំណុចខ្វះខាតសំខាន់នៃវិធីសាស្ត្រនេះគឺថា វាអាចរារាំងតុលាការពីការទទួលបាននូវទស្សនៈត្រឹមត្រូវជាច្រើន ទោះបីជាបញ្ហានេះអាចត្រូវបានកាត់បន្ថយដោយការតែងតាំងក្រុមអ្នកជំនាញ ឬតាមរយៈការអន្តរាគមន៍របស់ភាគីក្នុងដំណាក់កាលជម្រះក្តី។

## 3. លក្ខខណ្ឌសម្រាប់ភាពអាចទទួលយកបាននៃភស្តុតាងយោបល់អ្នកជំនាញ

3.1 នៅពេលដែលច្បាប់នៃយុត្តាធិការណាមួយអនុញ្ញាតឱ្យគូភាគីដឹកនាំភស្តុតាងអ្នកជំនាញ តុលាការអាចបដិសេធ ឬដាក់កម្រិតលើការប្រើប្រាស់ភស្តុតាងនោះ យោងទៅតាមវិធាននៃភស្តុតាងផ្ទាល់របស់តុលាការ។ អ្នកជំនាញសេដ្ឋកិច្ចដែលរក្សាទុកដើម្បីបង្ហាញភស្តុតាងសេដ្ឋកិច្ចនៅក្នុងតុលាការ ទំនងជាត្រូវបានគេទទួលដឹងថាជាសាក្សីដែលអាចជឿទុកចិត្តបាន និងមិនលម្អៀង ប្រសិនបើពួកគាត់ត្រូវបានស្នើសុំឱ្យពន្យល់ពីមូលហេតុដែលទ្រឹស្តីសេដ្ឋកិច្ចជាក់លាក់មានហេតុផល និងមូលហេតុដែលវាគួរត្រូវបានអនុវត្តចំពោះអង្គហេតុនៃករណីនោះ ជាជាងការឆ្លើយតបបទចោទចំពោះការអនុវត្តទ្រឹស្តីណាមួយ ដែលមានគោលបំណងតែមួយគត់គឺដើម្បីបម្រើប្រយោជន៍របស់អតិថិជន។ ពួកគេក៏អាចនាំមកនូវទស្សនៈថ្មីៗដែលមានប្រយោជន៍ផងដែរ។

3.2 តុលាការអាចរកភស្តុតាងដែលមិនអាចទទួលយកបាន ឬមានទម្ងន់តិចតួច អាស្រ័យលើវិធានពាក់ព័ន្ធនៃភស្តុតាងនោះ។ គួរកត់សម្គាល់ថាមានភាពខុសគ្នានៅទូទាំងយុត្តាធិការ ទាក់ទងនឹងវិសាលភាពដែលវិធាន និងទម្រង់ការដែលដាក់បទប្បញ្ញត្តិដល់សាក្សីជំនាញសេដ្ឋកិច្ច នៅក្នុងដំណើរការនីតិវិធីរបស់តុលាការដែលបានបង្កើតឡើង។

3.3 នៅប្រទេសអូស្ត្រាលី ភស្តុតាងអ្នកជំនាញដែលបានដាក់ជូនដោយភាគី អាចត្រូវបានគេរកឃើញថាមិនអាចទទួលយកបាន ឬមានទម្ងន់តិចតួច ប្រសិនបើ៖

a. សំណួរ ឬបញ្ហាជាក់លាក់ដែលអ្នកជំនាញគិតឃើញនោះ ស្ថិតនៅខាងក្រៅវិស័យជំនាញរបស់អ្នកជំនាញ។

b. ការណែនាំដែលបានផ្តល់ឱ្យអ្នកជំនាញមិនបានលាតត្រដាងឱ្យដឹង។

c. ការសន្មត ឬអង្គហេតុសំខាន់ចាំបាច់ដែលគាំទ្រគំនិត មិនបានលាតត្រដាងឱ្យដឹង ឬកែតម្រូវដោយភស្តុតាងផ្សេងទៀត។

d. អ្នកជំនាញមិនអាចធ្វើការសាកសួរទាំងអស់ ដែលអ្នកជំនាញជឿជាក់ថាគួរឱ្យចង់បាន និងសមរម្យ ឬ

e. មូលហេតុមិនត្រូវបានបញ្ជាក់ច្បាស់លាស់។

3.4 ក្នុងយុត្តាធិការខ្លះ តុលាការយល់ថាវាមានប្រយោជន៍ក្នុងការបង្កើតបញ្ជីសំណួរជាក់ស្តែងសម្រាប់ចៅក្រម ដើម្បីសាកសួរអ្នកជំនាញក្នុងគោលបំណងវាយតម្លៃភាពជឿជាក់របស់ពួកគេ។ សំណួរទាំងនេះអាចផ្តោតលើបញ្ហានៃភាពអាចជឿជាក់បាន ភាពជាប់ទាក់ទង និងភាពស្ថិតស្ថេរផ្ទៃក្នុង ក៏ដូចជាថាតើទ្រឹស្តីជឿនលឿនត្រូវបានគេបោះពុម្ព នៅក្នុងការបោះពុម្ពផ្សាយសម្រាប់ការពិនិត្យឡើងវិញរបស់អ្នកមានឋានៈស្មើគ្នាឬអត់។

## 4. អ្នកជំនាញដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ

4.1 ភស្តុតាងមតិរបស់អ្នកជំនាញនឹងមានតែជំនួយដល់តុលាការប៉ុណ្ណោះ ប្រសិនបើវាផ្អែកទាំងស្រុង ឬមួយផ្នែកធំទៅលើចំណេះដឹងដែលមានជំនាញដែលកើតឡើងពីការបណ្តុះបណ្តាល ការសិក្សា ឬបទពិសោធន៍របស់អ្នកជំនាញ។

4.2 ក្នុងការវាយតម្លៃទម្ងន់ដែលបានផ្តល់ជូនភស្តុតាងអ្នកជំនាញដែលបានដាក់ដោយភាគី ឬនៅពេលជ្រើសរើសអ្នកជំនាញដែលតែងតាំងដោយតុលាការ ចៅក្រមគួរតែពិចារណាពីលក្ខណៈសម្បត្តិរបស់អ្នកជំនាញ ក្នុងការឱ្យយោបល់លើសំណួរជាក់លាក់ ឬបញ្ហាដែលកើតឡើងនៅក្នុងករណីនោះ។ ឧទាហរណ៍ អ្នកសិក្សានៅក្នុងវិស័យសេដ្ឋកិច្ច ប្រហែលជាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីឱ្យយោបល់ពីការប្រតិបត្តិការនៃឧស្សាហកម្មជាក់លាក់ណាមួយ ដែលអ្នកសិក្សាមិនបានសិក្សា ឬធ្វើការនៅក្នុងវិស័យនោះទេ។

4.3 ភាពជឿជាក់របស់សាក្សីជំនាញដែលបានជ្រើសរើសដោយគូភាគី អាចជាប្រធានបទនៃការវាយតម្លៃអវិជ្ជមានដោយចៅក្រម ប្រសិនបើលក្ខណៈសម្បត្តិរបស់អ្នកជំនាញមិនរឹងមាំ ហើយមានចែងយ៉ាងច្បាស់លាស់នៅក្នុងភស្តុតាង ឬប្រសិនបើយោបល់របស់អ្នកជំនាញ ហាក់ដូចជាខ្វះលក្ខណៈស្របតាមការពិត ឬមានការប្រកាន់បក្សពួក។

## 5. របាយការណ៍អ្នកជំនាញ

5.1 ជាការអនុវត្តទូទៅនៅក្នុងពិភពលោក សម្រាប់ភស្តុតាងអ្នកជំនាញក្នុងបញ្ហាការប្រកួតប្រជែងត្រូវបានដាក់ជាទម្រង់នៃរបាយការណ៍អ្នកជំនាញ។ ខ្លឹមសារនៃរបាយការណ៍ទាំងនោះអាចត្រូវបានជំទាស់ ស្របតាមវិធានភស្តុតាងនៃយុត្តាធិការនីមួយៗ ឧទាហរណ៍ តាមរយៈការសាកសួរចម្លើយសាក្សីនៅក្នុងតុលាការ ឬតាមរយៈការដាក់របាយការណ៍អ្នកជំនាញពីភាគីផ្សេងទៀត។

5.2 របាយការណ៍អ្នកជំនាញនឹងបានជាជំនួយភាគច្រើនដល់តុលាការ ប្រសិនបើរបាយការណ៍នោះ៖

a. បង្ហាញយ៉ាងច្បាស់ ដោយរួមបញ្ចូលទាំងការសង្ខេបខ្លីៗនៅដើមដំបូង និងការបង្កើតហេតុផលសម្រាប់មតិនីមួយៗ ហើយចៀសវាងពីការប្រើពាក្យបច្ចេកទេសភាសាមិនច្បាស់លាស់ ក្នុងករណីដែលអាចធ្វើទៅបាន។

b. ការជាប់ទាក់ទិនដែលសំខាន់បំផុត ដើម្បីបង្ហាញពីមតិលើសំណួរ ឬបញ្ហាដែលបានកំណត់ច្បាស់លាស់ ជាជាងការនិយាយឥតចុងឥតដើម ឬការផ្តល់ទ្រឹស្តីទូទៅ និង

c. មិនប្រើសំឡេងតទល់គ្នា ឬករឿងគ្នា។

5.3 ជាពិសេសក្នុងករណីនៃអ្នកជំនាញដែលបានតែងតាំងដោយភាគីណាមួយ តុលាការអាចពិចារណាផងដែរថា តើរបាយការណ៍នោះមានដាក់បញ្ចូល៖

a. លក្ខណៈសម្បត្តិរបស់អ្នកជំនាញដែលបានរៀបចំវាឬអត់។

b. ការណែនាំដែលបានផ្តល់ឱ្យអ្នកជំនាញ រួមទាំងសំណួរជាក់លាក់ណាមួយដែលអ្នកជំនាញត្រូវបានស្នើសុំឱ្យដោះស្រាយ។

c. រាល់ការសន្មត និងអង្គហេតុសំខាន់ចាំបាច់ដែលមតិនីមួយៗមានជាមូលដ្ឋាន។

d. មូលហេតុ និងអក្សរសាស្ត្រពាក់ព័ន្ធ ឬសម្ភារៈផ្សេងទៀតដែលត្រូវបានប្រើប្រាស់ក្នុងការគាំទ្រមតិនីមួយៗ។

e. រាល់ការពិនិត្យ ធ្វើតេស្ត ឬការស៊ើបអង្កេតផ្សេងទៀតដែលអ្នកជំនាញបានពឹងផ្អែក រួមមានអត្តសញ្ញាណ និងលក្ខណៈសម្បត្តិរបស់បុគ្គលដែលបានរៀបចំ

f. លក្ខណៈពិសេសៗនៃមតិណាមួយដែលបានបញ្ចេញដោយមនុស្សម្នាក់ទៀត ដែលយោបល់របស់អ្នកជំនាញបានទទួលយក និងពឹងផ្អែកលើ។

g. ការបដិសេធដែលសមរម្យ ប្រសិនបើមានបញ្ហាណាមួយស្ថិតនៅខាងក្រៅវិស័យជំនាញរបស់អ្នកជំនាញ ឬប្រសិនបើយោបល់បញ្ចប់មិនអាចបង្ហាញបាន ដោយសារតែទិន្នន័យមិនគ្រប់គ្រាន់ ឬសម្រាប់ហេតុផលផ្សេងទៀត និង

h. លក្ខណៈសម្បត្តិសមស្របផ្សេងទៀតលើយោបល់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ ដែលប្រសិនបើគ្មានលក្ខណៈសម្បត្តិទាំងនេះទេ នោះរបាយការណ៍អាចមិនពេញលេញ ឬមិនត្រឹមត្រូវឡើយ។

## 6. ការប្រើប្រាស់សមស្របនៃភ័ស្តុតាងអ្នកជំនាញ និងសាក្សីជំនាញ

6.1 ការគ្រប់គ្រងភ័ស្តុតាងអ្នកជំនាញគឺចាំបាច់ក្នុងករណីនៃការប្រកួតប្រជែងភាគច្រើន។ ដូចដែលបានកត់សម្គាល់ខាងលើ យន្តការ និងអំណាចដែលមានសម្រាប់តុលាការដើម្បីគ្រប់គ្រងភ័ស្តុតាងអ្នកជំនាញ មានភាពខុសគ្នាទៅតាមយុត្តាធិការនីមួយៗ។

6.2 ដើម្បីសម្របសម្រួលការប្រើប្រាស់ភ័ស្តុតាងអ្នកជំនាញប្រកបដោយប្រសិទ្ធភាពនៅប្រទេសអូស្ត្រាលី តុលាការអាចស្វែងរកការកំណត់ជាមុន ទៅលើ៖

a. ចំនួនសាក្សីជំនាញដែលត្រូវបានដាក់ស្នើសម្រាប់ភាគីនីមួយៗពឹងផ្អែកលើ

b. ផ្នែកជំនាញរៀងៗខ្លួនរបស់ពួកគេ

c. បញ្ហាដែលត្រូវបានដាក់ស្នើអ្នកជំនាញម្នាក់ៗនឹងត្រូវដោះស្រាយ និង

d. របៀបដែលភ័ស្តុតាងអ្នកជំនាញអាចមានការគ្រប់គ្រងបានល្អបំផុត។

6.3 ជាញឹកញាប់ វាជាការប្រសើរដែលភាគីនានាគួរព្យាយាមដើម្បីយល់ព្រមជាមុនលើសំណួរ ឬបញ្ហាដែលបានដាក់ស្នើដើម្បីជាកម្មវត្ថុនៃភ័ស្តុតាងអ្នកជំនាញ ក៏ដូចជាអង្គហេតុពាក់ព័ន្ធ និងការសន្មតផងដែរ។ តុលាការអាចពិចារណាធ្វើការចេញសេចក្ដីបង្គាប់ដើម្បីជួយសម្រួលដល់បញ្ហានេះ។

6.4 ប្រសិនបើអាច ការចូលរួមដំបូងរបស់តុលាការក្នុងការគ្រប់គ្រងភ័ស្តុតាងអ្នកជំនាញ អាចធានាថារាល់សំណួរ ឬការសន្មតដែលបានផ្ដល់ជូនអ្នកជំនាញ ត្រូវបានផ្ដល់ជូនដោយមិនលម្អៀង និងតាមរបៀបដែលអ្នកជំនាញមិនត្រូវបានកំណត់ ដើម្បីដោះស្រាយបញ្ហាដែលជ្រើសរើស មិនពាក់ព័ន្ធ ឬមិនសំខាន់។ វាក៏អាចធានាផងដែរថា ភ័ស្តុតាងអ្នកជំនាញមិនត្រឹមតែពន្យល់ពីទ្រឹស្ដីសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិធីដែលអាចអនុវត្តបាននៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្ដីនៅចំពោះតុលាការផងដែរ។

6.5 ការគ្រប់គ្រងករណីល្អ ក៏អាចជំនះលើហានិភ័យជាច្រើននៃការប្រើប្រាស់ភ័ស្តុតាងអ្នកជំនាញផងដែរ រួមមានការគ្រប់គ្រង បរិមាណពេលវេលានៃការរៀបចំ និងថ្លៃដើមរបស់វា។

6.6 ទូទៅជាងនេះទៅទៀត គោលការណ៍សំខាន់ៗមួយចំនួនត្រូវបានកំណត់ដោយ OECD ដែលអាចជួយដល់តុលាការនៅពេលអ្នកជំនាញមានជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះក្ដីនៃច្បាប់ប្រកួតប្រជែង។ អ្នកជំនាញខាងសេដ្ឋកិច្ច មិនគួរពឹងផ្អែកថាជាសាក្សីពិតនោះឡើយ ផ្ទុយទៅវិញពួកគេគួរតែផ្ដោតលើការវិភាគសេដ្ឋកិច្ច ឬសេដ្ឋកិច្ចមាត្រសាស្ត្រនៃអង្គហេតុដែលបានណែនាំ និងបង្កើតរួចហើយតាមរយៈសាក្សីដទៃទៀត។ ទ្រឹស្ដីសេដ្ឋកិច្ច និងវិធីសាស្ត្រដែលជឿនលឿន គួរតែត្រូវធ្វើតេស្តឱ្យបានគ្រប់គ្រាន់នៅក្នុងសហគមន៍សេដ្ឋកិច្ច។ អ្នកជំនាញមិនគួរត្រូវបានកំណត់ឱ្យចង្អៀតនៅក្នុងទិន្នន័យដែលពួកគេវិភាគនោះទេ។ អ្នកជំនាញសេដ្ឋកិច្ចមិនគួរត្រូវបានដាក់ស្នើថាជាអ្នកជំនាញក្នុងវិស័យទេ បើមិនដូច្នេះទេ ភាពជឿជាក់របស់ពួកគេអាចនឹងរងការប៉ះពាល់ខ្លាំងក្នុងពេលជំនុំជម្រះ។ ជាចុងបញ្ចប់ វាជាការសំខាន់ដែលត្រូវចងចាំថា អ្នកជំនាញអាចមានទាំងតួនាទីវាយលុក និងការពារដើម្បីដើរតួក្នុងករណីដែលបានផ្ដល់ឱ្យ។

## 7. គំរូរបស់ភ័ស្តុតាងអ្នកជំនាញ

7.1 ប្រទេសអូស្ត្រាលីគឺជាយុត្តាធិការនៃច្បាប់ common law មួយ ដែលមានប្រព័ន្ធច្បាប់ផ្ដល់ឱ្យគូក្ដីតទល់គ្នា។ ដូច្នោះ ក្នុងរឿងក្ដីនានានៅចំពោះមុខតុលាការអូស្ត្រាលី ភាគីនីមួយៗនៃដំណើរការនីតិវិធីដែលជំទាស់ អាចស្វែងរកភ័ស្តុតាងដែលសំខាន់ជាងគេពីអ្នកជំនាញម្នាក់ ឬច្រើននាក់ដើម្បីគាំទ្ររឿងក្ដីរបស់ពួកគេ។ តាមទម្លាប់ ភ័ស្តុតាងបែបនេះត្រូវបានជំទាស់ដោយស្មាក្ដីជំទាស់ក្នុងអំឡុងពេលការសាកសួរចម្លើយសាក្សី។

7.2 ក្នុងករណីខ្លះ វិធីសាស្ត្រតាមទម្លាប់នេះចំពោះភ័ស្តុតាងអ្នកជំនាញ បានជាគំរូសមស្របបំផុតនៃការបង្ហាញភ័ស្តុតាងអ្នកជំនាញ។ ប្រព័ន្ធផ្សេងទៀតមានវិធីសាស្ត្រផ្សេងទៀតចំពោះភ័ស្តុតាងអ្នកជំនាញ ដែលនឹងអនុវត្តយ៉ាងល្អចំពោះរឿងក្ដីមួយចំនួន។ ឧទាហរណ៍ នៅក្នុងយុត្តាធិការនៃច្បាប់រដ្ឋប្បវេណី អ្នកជំនាញជាទូទៅត្រូវបានតែងតាំងរួមគ្នាដោយគូភាគី ឬដោយតុលាការតែប៉ុណ្ណោះ។

7.3 ក្នុងករណីណាក៏ដោយ វិធីសាស្ត្រផ្សេងទៀតចំពោះភ័ស្តុតាងអ្នកជំនាញអាចជាការប្រសើរសម្រាប់រឿងក្ដីនីមួយៗ។ នៅប្រទេសអូស្ត្រាលី ដែលតុលាការមានអំណាចគ្រប់គ្រងរឿងក្ដីយ៉ាងទូលំទូលាយ តុលាការអាចពិចារណាគំរូជម្រើសផ្សេងទៀតសម្រាប់ការបង្ហាញភ័ស្តុតាងអ្នកជំនាញ។

7.4 គំរូជម្រើសផ្សេងមួយដែលអាចត្រូវបានពិចារណា គឺការផ្ដល់ភ័ស្តុតាងអ្នកជំនាញស្របពេលជាមួយគ្នា ដែលត្រូវបានគេស្គាល់នៅប្រទេសអូស្ត្រាលីថា ‘ធុងងូតទឹកក្ដៅ’។ វិធីសាស្ត្រនេះត្រូវបានគេប្រើជាទូទៅនៅក្នុងករណីនៃច្បាប់ការប្រកួតប្រជែងរបស់

ប្រទេសអូស្ត្រាលី ក៏ដូចជានៅបរទេសនូវែលសេឡង់ ហើយម្តងម្កាលនៅចក្រភពអង់គ្លេស។ វាពាក់ព័ន្ធនឹងអ្នកជំនាញរៀបចំរបាយការណ៍រួមមួយ ដែលកំណត់កន្លែងដែលពួកគេយល់ស្រប និងកន្លែងដែលពួកគេមិនយល់ស្រប។ អ្នកសម្របសម្រួលឯករាជ្យម្នាក់អាចត្រូវបានគេតែងតាំងដើម្បីត្រួតពិនិត្យដំណើរការនេះ។ នៅពេលសវនាការអ្នកជំនាញត្រូវបានកោះហៅឱ្យផ្តល់ភ័ស្តុតាងក្នុងពេលតែមួយ។ ដំណើរការនៃការផ្តល់ភ័ស្តុតាងស្របពេលជាមួយគ្នា គួរតែអនុញ្ញាតឱ្យមានការផ្លាស់ប្តូរដែលមានលំដាប់សមរម្យ ហើយមានសណ្តាប់ធ្នាប់រវាងសាក្សីជំនាញសម្រាប់ភាគីនីមួយៗ ក៏ដូចជារវាងសាក្សីជំនាញនីមួយៗ មេធាវីសម្រាប់ភាគីនីមួយៗ និងតុលាការដែរ។ នៅក្នុងសវនាការ សាក្សីជំនាញអាចត្រូវបានផ្តល់ឱកាសដើម្បីផ្តល់នូវសេចក្តីសង្ខេបនៃគំនិតរបស់ពួកគេ ហើយពន្យល់ពីអ្វីដែលពួកគេចាត់ទុកថាជាបញ្ហាចម្បងនៃការមិនចុះសម្រុងគ្នារវាងអ្នកជំនាញ ដូចដែលពួកគេបានឃើញ ជាពាក្យរបស់ពួកគេផ្ទាល់។

## 8. ប្រភពព័ត៌មានពាក់ព័ន្ធ

8.1 ធនធានខាងក្រោម ផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងការប្រើប្រាស់នៃភ័ស្តុតាងសំអាងលើហេតុការណ៍នៅក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង។ ឯកសារនេះប្រើជាឯកសារយោងទូទៅដ៏មានប្រយោជន៍ សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន៖

a. ចៅក្រម Middleton *ភ័ស្តុតាងសេដ្ឋកិច្ចអ្នកជំនាញ* ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧

b. OECD *ការបង្ហាញទ្រឹស្តីសេដ្ឋកិច្ចស្មុគស្មាញដល់ចៅក្រម* ឆ្នាំ២០០៨

c. OECD *យុត្តិធម៌នីតិវិធី៖ អាជ្ញាធរប្រកួតប្រជែង តុលាការ និងការអភិវឌ្ឍថ្មីៗ* ឆ្នាំ២០១១

d. ចៅក្រម Rares *ការប្រើប្រាស់ "ធុងងូតទឹកក្តៅ" - របៀបដែលភ័ស្តុតាងអ្នកជំនាញផ្តល់ស្របពេលជាមួយគ្នាជួយដល់ការយល់ដឹងអំពីបញ្ហា"* ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៣

e. តុលាការសហព័ន្ធអូស្ត្រាលី (Federal Court of Australia) *កំណត់សម្គាល់ការអនុវត្តភ័ស្តុតាងអ្នកជំនាញ (GPN-EXPT)* ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

f. OECD *ដំណោះស្រាយនៃករណីប្រកួតប្រជែងដោយតុលាការអ្នកជំនាញ និងអ្នកឯកទេស៖ ការជ្រើសរើសពីក័ណ្ឌបទពិសោធអន្តរជាតិ* ឆ្នាំ២០១៦

g. Federal Court of Australia *ការណែនាំភ័ស្តុតាងអ្នកជំនាញ និងសាក្សីជំនាញ*

# សៀវភៅមូលដ្ឋានសម្រាប់ចៅក្រមអាស៊ានស្ដីពីការប្រកួតប្រជែង

បង្កើតឡើងជាផ្នែកនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែងរបស់ AANZFTA
(AANZFTA Competition Law Implementation Program)

## *ភស្តុតាងសំអាងលើហេតុការណ៍នៅក្នុងបរិបទនៃច្បាប់ប្រកួតប្រជែង*

## 1. សេចក្ដីផ្ដើម

1.1 សៀវភៅមូលដ្ឋាននេះ មានគោលបំណងដើម្បី៖

a. ធ្វើជាឯកសារផ្អែកលើគោលការណ៍សម្រាប់ការប្រើប្រាស់ដោយសមាជិកតុលាការ ក្នុងរដ្ឋជាសមាជិកនីមួយៗរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (Association of Southeast Asian Nations) (‘ASEAN’)។

b. ផ្ដល់នូវមគ្គុទេសក៍ជាក់ស្ដែង និងផ្ដល់ព័ត៌មានដល់ចៅក្រមដោយផ្ដោតលើការប្រឈម និងបញ្ហាដែលជួបប្រទះនៅក្នុងការវាយតម្លៃភស្តុតាងស្មុគស្មាញពីអ្នកជំនាញក្នុងពេលធ្វើការ និងពិនិត្យសេចក្ដីសម្រេចនានាក្រោមច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន និង

c. ជួយក្នុងការអភិវឌ្ឍច្បាប់ប្រកួតប្រជែងពីមុន ដែលបង្កើនភាពច្បាស់លាស់ផ្នែកច្បាប់ លើកកម្ពស់ប្រសិទ្ធភាព និងជំរុញសង្គតិភាព និងភាពអាចព្យាករណ៍បាននៅក្នុងបណ្ដារដ្ឋជាសមាជិកអាស៊ាន និងចុងក្រោយ ចូលរួមចំណែកក្នុងការកំណត់គោលនយោបាយការប្រកួតប្រជែងមានលក្ខណៈល្អប្រសើរ។

1.2 សៀវភៅមូលដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃភាពផ្សេងគ្នា និងដំណាក់កាលខុសៗគ្នានៃការរៀបចំច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ សៀវភៅនេះមិនមានបំណងផ្ដល់ព័ត៌មានជាក់លាក់ទៅតាមប្រទេសនីមួយៗទេ។

1.3 សៀវភៅមូលដ្ឋាននេះត្រូវបានបង្កើតឡើងដោយចៅក្រមនៃតុលាការសហព័ន្ធអូស្ត្រាលី សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយ OECD។ នេះគឺជាសៀវភៅមួយនៅក្នុងចំណោមសៀវភៅមូលដ្ឋានស្ដីពីច្បាប់ប្រកួតប្រជែងជាបន្តបន្ទាប់ ដែលត្រូវបានបង្កើតឡើងតាមគំនិតផ្ដួចផ្ដើមរបស់គណៈកម្មការប្រកួតប្រជែងតំបន់ពាណិជ្ជកម្មសេរីអាស៊ានអូស្ត្រាលីនូវែលសេឡង់ (ASEAN Australia New Zealand Free Trade Area Competition Committee) ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program) (‘CLIP’)។

## 2. តើអ្វីជាភ័ស្តុតាងសំអាងលើហេតុការណ៍?

2.1 ភាគីមួយអាចបង្ហាញភ័ស្តុតាងពីអង្គហេតុនៅក្នុងដំណើរការនីតិវិធីៈ

a. ដោយមានភ័ស្តុតាងផ្ទាល់ ដោយការនាំទៅរកភ័ស្តុតាងនៃអង្គហេតុនោះ ឬ

b. ដោយមានភ័ស្តុតាងសំអាងលើហេតុការណ៍ ដោយនាំទៅរកភ័ស្តុតាងនៃអង្គហេតុមួយ ឬអង្គហេតុផ្សេងទៀតដែលតុលាការអាចត្រូវបានហៅឱ្យទាញសេចក្តីសន្និដ្ឋានអំពីអង្គហេតុជាក់លាក់នៅក្នុងរឿងហេតុ។

2.2 ភាពខុសគ្នារវាងភ័ស្តុតាងផ្ទាល់ និងភ័ស្តុតាងសំអាងលើហេតុការណ៍ គឺថាភ័ស្តុតាងផ្ទាល់មិនតម្រូវឱ្យមានដំណើរការនៃការសន្និដ្ឋានហេតុផលសមហេតុផលឡើយ។ ក្នុងករណីកាតែល (ក្រុមហ៊ុនអន្តរជាតិផ្តាច់មុខ) ភ័ស្តុតាងផ្ទាល់នឹងកំណត់ការប្រជុំ ឬការប្រាស្រ័យទាក់ទងគ្នារវាងប្រធានបទនានា និងពិពណ៌នាពីខ្លឹមសារនៃកិច្ចព្រមព្រៀងរបស់ពួកគេ។ ភ័ស្តុតាងសំអាងលើហេតុការណ៍ នឹងមិនកំណត់ជាក់លាក់ពីធាតុផ្សំទាំងនេះទេ ក៏ប៉ុន្តែនឹងអនុញ្ញាតឱ្យតុលាការសន្និដ្ឋានថាកិច្ចព្រមព្រៀងបានកើតឡើងចំពោះភាគីពាក់ព័ន្ធ និងខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។ ឧទាហរណ៍ អ្នកបម្រើស្រីនៅភោជនីយដ្ឋានម្នាក់ នៅក្នុងការប្រជុំអាហារថ្ងៃត្រង់រវាងអ្នកប្រកួតប្រជែងបីនាក់ អាចផ្តល់ភស្តុតាងថានាងបានស្តាប់ឮសូរអ្នកប្រកួតប្រជែងពីរនាក់ឈានដល់កិច្ចព្រមព្រៀងកាតែល ហើយបានឃើញពួកគេទាំងបីនាក់យកដៃទះបន្ទើរៗពីក្រោយខ្នងគ្នានៅចុងបញ្ចប់នៃកិច្ចប្រជុំ។ ទោះបីវាគ្រាន់តែផ្តល់ភ័ស្តុតាងផ្ទាល់អំពីកិច្ចព្រមព្រៀងរវាងអ្នកប្រកួតប្រជែងពីរនាក់ក៏ដោយ ចៅក្រមអាចមានលទ្ធភាពធ្វើការសន្និដ្ឋានពីកិច្ចព្រមព្រៀងកាតែលរបស់ត្រីភាគីនោះចេញពីកាលៈទេសៈនានា។

## 3. តួនាទីនៃ ភ័ស្តុតាងសំអាងលើហេតុការណ៍ នៅក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង

3.1 សំណុំរឿងច្បាប់ប្រកួតប្រជែងកម្រនឹងផ្អែកលើភ័ស្តុតាងផ្ទាល់ទាំងស្រុងណាស់។ ផ្ទុយទៅវិញ សំណុំរឿងច្បាប់ប្រកួតប្រជែង ជាទូទៅផ្អែកលើភ័ស្តុតាង រួមទាំងភ័ស្តុតាងសំអាងលើហេតុការណ៍ និងភ័ស្តុតាងផ្ទាល់ ឬភ័ស្តុតាងសំអាងលើហេតុការណ៍ទាំងមូល។ កន្លែងណាមានភ័ស្តុតាងផ្ទាល់ ភ័ស្តុតាងសំអាងលើហេតុការណ៍ អាចជួយចៅក្រមក្នុងការវាយតម្លៃភាពជឿជាក់នៃភ័ស្តុតាងនោះ។ ឧទាហរណ៍ ភ័ស្តុតាងផ្ទាល់ទាក់ទងនឹងការប្រជុំរវាងអ្នកប្រកួតប្រជែង អាចត្រូវបានអះអាងបន្ថែម ឬផ្ទុយគ្នាពីភ័ស្តុតាងសំអាងលើហេតុការណ៍ ដូចជាកំណត់ត្រាធ្វើដំណើរជាដើម។

3.2 ភ័ស្តុតាងសំអាងលើហេតុការណ៍ត្រូវបានទទួលយកនៅគ្រប់បណ្តាប្រទេស OECD និងនៅក្នុងដែនយុត្តាធិការផ្សេងៗទៀតជាច្រើន។ កត្តានេះឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃភស្តុតាងប្រភេទនេះ សម្រាប់ការអនុវត្តច្បាប់ប្រកួតប្រជែងឱ្យទទួលបានជោគជ័យ។

3.3 ក្នុងករណីកាតែល ប្រតិបត្តិករកាតែលដែលជឿនលឿន ដឹងថាការប្រព្រឹត្តរបស់ខ្លួនគឺខុសច្បាប់ ហើយអតិថិជនរបស់ពួកគេនឹងបដិសេធចំពោះការប្រព្រឹត្តនោះ ប្រសិនបើពួកគេដឹងអំពីករណីនេះ។ ពួកគេអាចចាត់វិធានការដើម្បីលាក់បាំងការប្រព្រឹត្តរបស់ខ្លួន និងចៀសវាងចូលទៅក្នុងការរៀបចំជាផ្លូវការ និងរៀបចំជាឯកសារ។ ជាការពិត ជាទូទៅនៅទូទាំងយុត្តាធិការ កាតែលដាក់បញ្ចូលកិច្ចព្រមព្រៀងក្រៅផ្លូវការ ការយល់ដឹង “ការប្រសប់គំនិត” ឬ “ការប្តេជ្ញាចិត្តប្រកបដោយឆន្ទៈចំពោះគ្រោងការណ៍រួម”។ ការប៉ុនប៉ងលាក់បាំងនេះមានន័យថា ភ័ស្តុតាងផ្ទាល់នៃកិច្ចព្រមព្រៀងរបស់កាតែលនេះ ប្រហែលជាមិនមានទេ។ ក្នុងករណីបែបនេះ ភ័ស្តុតាងល្អបំផុតដែលប្រហែលជាអាចមានអំពីកិច្ចព្រមព្រៀងរវាងអ្នកប្រកួតប្រជែង គឺភ័ស្តុតាងសំអាងលើហេតុការណ៍នៃការប្រាស្រ័យទាក់ទងគ្នារវាងពួកគេ។

3.4 ប្រទេសមួយដែលមានរបបអនុវត្តច្បាប់ថ្មី និង/ឬកខ្វះវប្បធម៌ប្រកួតប្រជែងខ្លាំងអាចប្រឈមនឹងឧបសគ្គជាពិសេសក្នុងការទទួលបានភស្តុតាង ហើយជាពិសេសភស្តុតាងផ្ទាល់នៃការប្រព្រឹត្តដែលប្រឆាំងនឹងការប្រកួតប្រជែង។ ប្រទេសនេះប្រហែលជាមិនមានកម្មវិធីសេចក្តីអត់ឱនដ៏មានប្រសិទ្ធភាពឡើយ (ដែលជាប្រភពដើមនៃភស្តុតាងផ្ទាល់) ហើយក៏មិនអាចបង្កើតកិច្ចសហប្រតិបត្តិការជាមួយបុគ្គល ឬអាជីវកម្មដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលអាចជួយសម្រួលដល់ការប្រមូលភស្តុតាងនោះដែរ។ លើសពីនេះទៀត ការទទួលបានភស្តុតាងផ្ទាល់នៃកិច្ចព្រមព្រៀងរបស់កាតែល អាចតម្រូវឱ្យមានអំណាចការស៊ើបអង្កេតពិសេស ឧបករណ៍ និងបច្ចេកទេសដែលអាចធ្វើឡើងបានត្រឹមតែពីអាជ្ញាធរដែលមិនសូវមានបទពិសោធន៍ ឬអាជ្ញាធរថ្មីតែប៉ុណ្ណោះ។ ចំណុចនេះអាចមានន័យថាទីភ្នាក់ងារប្រកួតប្រជែងនៅក្នុងយុត្តាធិការបែបនេះ នឹងមានការលំបាកកាន់តែខ្លាំងក្នុងការបង្កើតភស្តុតាងផ្ទាល់នៅក្នុងករណីកាតែល ហើយត្រូវពឹងផ្អែកកាន់តែខ្លាំងលើភស្តុតាងសំអាងលើហេតុការណ៍។

3.5 ការភាន់ច្រឡំជាទូទៅគឺថា ករណីដែលផ្អែកលើភស្តុតាងផ្ទាល់ ចាំបាច់ត្រូវតែខ្លាំងជាងករណីដែលផ្អែកលើភស្តុតាងសំអាងលើហេតុការណ៍។ ចំណុចនេះមិនត្រឹមត្រូវរហូតទេ។ ករណីដែលផ្អែកលើភស្តុតាងផ្ទាល់ទាំងមូលរបស់សាក្សីម្នាក់ ឬច្រើននាក់នឹងត្រូវបរាជ័យប្រសិនបើតុលាការរកឃើញភស្តុតាងរបស់ពួកគេថាខ្វះការជឿទុកចិត្ត។ ទន្ទឹមក្នុងពេលជាមួយគ្នានេះ ភស្តុតាងសំអាងលើហេតុការណ៍អាចចង្អុលបង្ហាញយ៉ាងខ្លាំង សំដៅទៅការប្រព្រឹត្តបទល្មើសដែលគ្មានការសន្និដ្ឋានសមហេតុផលណាមួយផ្សេងទៀតត្រូវបានទុកចំហឡើយ។

3.6 អាស្រ័យលើស្តង់ដារនៃភស្តុតាងដែលត្រូវមាននៅក្នុងករណីជាក់លាក់មួយ សេចក្តីសន្និដ្ឋានដែលតុលាការត្រូវបានហៅឱ្យទាញចេញពីភស្តុតាងនោះ ចាំបាច់ត្រូវតែជាការសន្និដ្ឋានដែលសមហេតុផលតែមួយគត់ដែលអាចរកបាន ឬគ្រាន់តែជាការសន្និដ្ឋានដែលទំនងបំផុតប៉ុណ្ណោះ។

## 4. ប្រភេទផ្សេងគ្នានៃភស្តុតាងសំអាងលើហេតុការណ៍

4.1 មានភស្តុតាងសំអាងលើហេតុការណ៍ប្រភេទផ្សេងៗគ្នា ដែលអាចជាជំនួយដល់តុលាការ។ ឧទាហរណ៍ នៅក្នុងករណីកាតែល ភស្តុតាងសំអាងលើហេតុការណ៍ ជាទូទៅអាចត្រូវបានបែងចែកជាភស្តុតាងប្រាស្រ័យទាក់ទងគ្នា និងភស្តុតាងសេដ្ឋកិច្ច។

4.2 ភស្តុតាងប្រាស្រ័យទាក់ទងគ្នាដែលសំអាងលើហេតុការណ៍ គឺជាភស្តុតាងដែលបង្ហាញថាការប្រាស្រ័យទាក់ទងគ្នារវាងអ្នកប្រកួតប្រជែងបានកើតឡើង ទោះបីជាមិនមានខ្លឹមសារក៏ដោយ។ ភស្តុតាងប្រាស្រ័យទាក់ទងគ្នាដែលសំអាងលើហេតុការណ៍ អាចរួមមាន៖

a. កំណត់ត្រាទូរស័ព្ទ ដូចជាកំណត់ហេតុការហៅទូរស័ព្ទ និងទិន្នន័យតាមដានទីតាំង

b. កំណត់ហេតុ ឬប្រតិទិនប្រចាំថ្ងៃ

c. កំណត់ត្រាហិរញ្ញវត្ថុ ដូចជាបង្កាន់ដៃអាហារ ឬកន្លែងស្នាក់នៅ ការដាក់អ្នកប្រកួតប្រជែងនៅទីតាំងតែមួយ ក្នុងពេលតែមួយ។

d. កំណត់ចំណាំពីការប្រជុំ ដែលអាចកត់ត្រាពីការចូលរួម និងប្រធានបទធំៗនៃការពិភាក្សា និង

e. ឯកសារផ្ទៃក្នុង បង្ហាញពីការប្រាស្រ័យទាក់ទងគ្នាដែលបានកើតឡើងរវាងអ្នកប្រកួតប្រជែង។

4.3 ភ័ស្តុតាងសេដ្ឋកិច្ចដែលសំអាងទៅលើហេតុការណ៍ មានរួមមានភ័ស្តុតាងការប្រព្រឹត្ត និងភ័ស្តុតាងរចនាសម្ព័ន្ធ។ គួរពិចារណាទៅលើភ័ស្តុតាងទាំងពីរប្រភេទ។

4.4 ភ័ស្តុតាងការប្រព្រឹត្ត គឺជាភស្តុតាងដែលបញ្ជាក់ថា អ្នកប្រកួតប្រជែងមានឥរិយាបថជាប់លាប់ ជាមួយនឹងអត្ថិភាពនៃកិច្ចព្រមព្រៀងកាតែលដែលបានចោទប្រកាន់។ ភ័ស្តុតាងការប្រព្រឹត្តនឹងមានលក្ខណៈជឿជាក់បំផុតប្រសិនបើវាមិនអាចពន្យល់បានដោយកម្លាំងទីផ្សារធម្មតា ឬអាកប្បកិរិយាអាជីវកម្មដែលមានការប្រកួតប្រជែង។ ចៅក្រមគួរពិចារណាថាតើអាកប្បកិរិយាជាក់លាក់ណាមួយមុខជាបានកើតឡើងក្នុងករណីគ្មានកាតែល ទាក់ទងនឹងផលប្រយោជន៍ពាណិជ្ជកម្ម និងសេដ្ឋកិច្ចឯកតោភាគីរបស់អ្នកប្រកួតប្រជែង។ ភ័ស្តុតាងការប្រព្រឹត្ត អាចរួមមានភ័ស្តុតាងនៃការប្រព្រឹត្តស្របគ្នា លំនាំដេញថ្លៃ ការផ្លោះប្តូរព័ត៌មានរវាងអ្នកប្រកួតប្រជែង ប្រាក់ចំណេញដែលមាននិរន្តរភាពខ្ពស់មិនធម្មតា និងការរំលោភបំពានលើច្បាប់ប្រកួតប្រជែងកន្លងមក។

4.5 ភ័ស្តុតាងរចនាសម្ព័ន្ធ គឺជាភ័ស្តុតាងដែលពន្យល់ពីមូលហេតុដែលលក្ខណៈពិសេសនៃរចនាសម្ព័ន្ធជាក់លាក់ធ្វើឱ្យទីផ្សារជាក់លាក់ងាយនឹងទទួលរងពីការប្រព្រឹត្តរបស់កាតែល។ ភ័ស្តុតាងរចនាសម្ព័ន្ធតែឯងនោះគឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញពីអត្ថិភាពនៃអាកប្បកិរិយារបស់កាតែលទេ ក៏ប៉ុន្តែអាចប៉ះពាល់ដល់ការវាយតម្លៃរបស់ចៅក្រមអំពីភាពអាចមានឡើងនៃការប្រព្រឹត្តបែបនេះ នៅក្នុងទីផ្សារជាក់លាក់មួយ។ ភ័ស្តុតាងរចនាសម្ព័ន រួមមានភ័ស្តុតាងអំពីចំនួនអ្នកប្រកួតប្រជែង ការប្រមូល ផ្តុំទីផ្សារ ឧបសគ្គក្នុងការចូលការធ្វើសមាហរណកម្មបញ្ឈរ តម្លាភាពតម្លៃ និងភាពដូចគ្នានៃផលិតផល។ វាគឺជាតួយ៉ាងឧទាហរណ៍ធម្មតានៃភស្តុតាងសេដ្ឋកិច្ចដែលត្រូវបានពិភាក្សាលម្អិតបន្ថែមទៀតនៅក្នុងសៀវភៅមូលដ្ឋានរបស់ CLIP ស្តីពីការប្រកួតប្រជែង (CLIP Competition Primer) ស្តីពី ‘ភ័ស្តុតាងសេដ្ឋកិច្ច’ និង ‘ភ័ស្តុតាងអ្នកជំនាញ’។

## 5. ការវាយតម្លៃភ័ស្តុតាងទាំងមូល

5.1 ភ័ស្តុតាងសំអាងលើហេតុការណ៍មួយចំណែកអាចមានសមត្ថភាពទ្រទ្រង់សេចក្តីសន្និដ្ឋានមួយចំនួន ដែលមានខ្លះអាចប្រទាំងនឹងគ្នា (សូមមើល 5.2 et seq. នៅក្នុង CLIP Competition Primer ស្តីពី ‘ការរំលោភបំពានតួនាទីគ្របដណ្តប់’)។ ឧទាហរណ៍ការកាត់បន្ថយតម្លៃ អាចផ្តល់ការសន្និដ្ឋានសមរម្យថាជាការកំណត់តម្លៃដែលកេងប្រវ័ញ្ច ឬជាសេចក្តីសន្និដ្ឋានថាការប្រព្រឹត្តដែលមានការប្រកួតប្រជែង។ ដោយហេតុផលនេះ ភ័ស្តុតាងសំអាងលើហេតុការណ៍មិនគួរត្រូវបានវាយតម្លៃដាច់ដោយឡែកពីគេទេ។

5.2 សេចក្តីសន្និដ្ឋានដែលត្រូវធ្វើឡើង ចេញពីភ័ស្តុតាងសំអាងលើហេតុការណ៍ គួរតែត្រូវបានវាយតម្លៃទាំងមូលដោយចៅក្រមដោយគិតពិចារណាពីភ័ស្តុតាងដែលមានទាំងអស់។ ដោយលើកយកករណីកាតែល ដែលមានភ័ស្តុតាងបង្ហាញពី៖

a. ការហៅទូរស័ព្ទរវាងអ្នកប្រកួតប្រជែង នៅកាលបរិច្ឆេទបីផ្សេងគ្នា។

b. ការកើនតម្លៃស្របគ្នាធ្វើឡើងដោយអ្នកប្រកួតប្រជែងទាំងនោះ ពីរបីថ្ងៃបន្ទាប់ពីការហៅទូរស័ព្ទនីមួយៗ និង

c. រចនាសម្ព័នទីផ្សារដែលមានចំនួនអ្នកលក់តិចអាចលក់តម្លៃថោក ឬថ្លៃ។

5.3 នៅក្នុងឧទាហរណ៍ខាងលើ ហើយប្រសិនបើត្រូវបានពិចារណាដាច់ដោយឡែកពីគ្នា គ្មានភស្តុតាងសំអាងលើហេតុការណ៍ណាមួយ ដែលអាចផ្តល់ជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីសន្និដ្ឋានពីការឃុបឃិតគ្នានោះទេ។ ទោះយ៉ាងណាក្តី ការវាយតម្លៃទាំងបីរួមលើគ្នា អាចធ្វើឱ្យមានការសន្និដ្ឋានសមហេតុផលពីការប្រព្រឹត្តរបស់កាតែល។ ការពិចារណានេះអាចអនុវត្តបានចំពោះករណីជាច្រើនដែលភស្តុតាងសំអាងលើហេតុការណ៍ត្រូវបានពឹងផ្អែកលើ ដ្បិតអីជាទូទៅ ភស្តុតាងសំអាងលើហេតុការណ៍តែមួយគត់ អាចមិនផ្តល់នូវការសន្និដ្ឋានពេញលេញនៃការប្រព្រឹត្តដែលប្រឆាំងនឹងការប្រកួតប្រជែងឡើយ។

## 6. ឧទាហរណ៍នៃភស្តុតាងសំខាន់នៅក្នុងករណីកាតែល

6.1 នៅប្រទេសអូស្ត្រាលី ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនពីករណីកាតែល ដែលភស្តុតាងសំអាងលើហេតុការណ៍បានដើរតួយ៉ាងសំខាន់៖

a. ភស្តុតាងផ្ទាល់នៃកិច្ចព្រមព្រៀងរវាងម្ចាស់សណ្ឋាគារ ដើម្បីបញ្ឈប់ការបញ្ចុះថ្លៃស្រាបៀរក្នុងកញ្ចប់របស់ពួកគេ ត្រូវបានបដិសេធនៅក្នុងការជំនុំជម្រះក្តី បន្ទាប់ពីសាក្សីសំខាន់មិនបានគោរពតាមសេចក្តីថ្លែងមុនរបស់គាត់។ អត្ថិភាពនៃកិច្ចព្រមព្រៀងដែលបានចោទប្រកាន់នៅតែអាចសន្និដ្ឋានបាន រាប់បញ្ចូលទាំងពីភស្តុតាងការប្រាស្រ័យទាក់ទងដែលសំអាងលើហេតុការណ៍ និងភស្តុតាងការប្រព្រឹត្ត។

b. ក្រុមហ៊ុនសាងសង់ដែលដេញថ្លៃគម្រោងរដ្ឋាភិបាល ត្រូវគេរកឃើញថាបានឃុបឃិតគ្នាក្នុងអំឡុងដំណើរការដេញថ្លៃ។ ក្រុមហ៊ុនដែលមិនចង់ឈ្នះការដេញថ្លៃ បានស្វែងរក "ថ្លៃគ្រប (cover price)" សម្រាប់គម្រោង។ មានការសន្និដ្ឋានថាមានការព្រមព្រៀងមួយដែលក្រុមហ៊ុនស្វែងរកថ្លៃគ្រប នឹងដេញថ្លៃខ្ពស់ជាងតម្លៃនោះ ខណៈក្រុមហ៊ុនដែលផ្តល់ឱ្យនឹងដេញថ្លៃនៅខាងក្រោមថ្លៃគ្របនោះ។

c. ក្រុមហ៊ុនផលិតខ្សែកាបមួយត្រូវគេរកឃើញថា បានចូលរួមដេញថ្លៃដោយប្រើមធ្យោបាយមិនសុចរិត នៅក្នុងការដេញថ្លៃសម្រាប់ការផ្គត់ផ្គង់ខ្សែកាបដឹកម្លាំងវ៉ុលខ្ពស់ជូនគម្រោងវារីអគ្គិសនីមួយ។ មានការសន្និដ្ឋានថា ក្រុមហ៊ុនផលិតដែលកំពុងត្រូវពិចារណាបានស្នើសុំ "អាទិភាព" ក្នុងការដេញថ្លៃគម្រោងនោះ ដែលផ្តល់នូវប្រសិទ្ធិភាពដល់ការរៀបចំបណ្តាញកាតែលពិភពលោក រវាងអ្នកផ្គត់ផ្គង់ខ្សែកាបអ៊ឺរ៉ុប និងជប៉ុន សម្រាប់ការបែងចែកនៃគម្រោងនៅជុំវិញពិភពលោក។

## 7. ប្រភពព័ត៌មានពាក់ព័ន្ធ

7.1 ធនធានខាងក្រោម ផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងការប្រើប្រាស់នៃភ័ស្តុតាងសំអាងលើហេតុការណ៍នៅក្នុងសំណុំរឿងច្បាប់ប្រកួតប្រជែង។ ឯកសារនេះប្រើជាឯកសារយោងទូទៅដ៏មានប្រយោជន៍ សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន៖

a. គោលនយោបាយតុមូលរបស់ OECD ស្តីពីការប្រកួតប្រជែង (OECD Competition Policy Roundtables) *ការកាត់ទោសកាតែលដោយគ្មានភ័ស្តុតាងផ្ទាល់* ឆ្នាំ២០០៦

b. របាយការណ៍សង្ខេបស្តីពីគោលនយោបាយ OECD (OECD Policy Brief) *ការកាត់ទោសកាតែលដោយគ្មានភ័ស្តុតាងផ្ទាល់នៃកិច្ចព្រមព្រៀង* ខែមិថុនា ឆ្នាំ២០០៧

c. ចៅក្រម Mansfield *ឱកាស និងបញ្ហាប្រឈម៖ ភ័ស្តុតាងក្នុងករណីដែលស្ថិតក្រោមច្បាប់អនុវត្តពាណិជ្ជកម្ម ឆ្នាំ១៩៧៤* ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

d. គណៈកម្មាធិការប្រកួតប្រជែង និងអ្នកប្រើប្រាស់អូស្ត្រាលី (Australian Competition and Consumer Commission) *ការសិក្សាអំពីករណីកាតែល និងសំណុំរឿងច្បាប់*

e. បណ្តាញប្រកួតប្រជែងអន្តរជាតិ (International Competition Network) *ការផ្តល់កិច្ចព្រមព្រៀង ឬការប្រតិបត្តិការព្រមព្រៀងគ្នាដោយមានភ័ស្តុតាងប្រយោល*

FEDERAL COURT OF AUSTRALIA

OECD

ASEAN-Australia-New Zealand Free Trade Area (AANZFTA) Economic Cooperation Support Program (AECSP)

# សៀវភៅមូលដ្ឋានសម្រាប់ចៅក្រមអាស៊ានស្តីពីការប្រកួតប្រជែង

បង្កើតឡើងជាផ្នែកនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែងរបស់ AANZFTA
(AANZFTA Competition Law Implementation Program)

## *ការរំលោភបំពានលើតួនាទីគ្របដណ្តប់៖ តើវាជាអ្វី ហើយតើគេវាយតម្លៃវាយ៉ាងដូចម្តេច?*

### 1. សេចក្តីផ្តើម

1.1 សៀវភៅមូលដ្ឋាននេះ មានគោលបំណងដើម្បី៖

a. ធ្វើជាឯកសារផ្អែកលើគោលការណ៍សម្រាប់ការប្រើប្រាស់ដោយសមាជិកតុលាការ ក្នុងរដ្ឋជាសមាជិកនីមួយៗរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (Association of Southeast Asian Nations) (‘ASEAN’)។

b. ផ្តល់នូវមគ្គុទេសក៍ជាក់ស្តែង និងផ្តល់ព័ត៌មានដល់ចៅក្រមដោយផ្តោតលើការប្រឈម និងបញ្ហាដែលជួបប្រទះនៅក្នុងការវាយតម្លៃភ័ស្តុតាងស្មុគស្មាញពីអ្នកជំនាញក្នុងពេលធ្វើការ និងពិនិត្យសេចក្តីសម្រេចនានាក្រោមច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន និង

c. ជួយក្នុងការអភិវឌ្ឍច្បាប់ប្រកួតប្រជែងពីមុន ដែលបង្កើនភាពច្បាស់លាស់ផ្នែកច្បាប់ លើកកម្ពស់ប្រសិទ្ធភាព និងជំរុញសង្គតិភាព និងភាពអាចព្យាករណ៍បាននៅក្នុងបណ្តារដ្ឋជាសមាជិកអាស៊ាន និងចុងក្រោយ ចូលរួមចំណែកក្នុងការកំណត់គោលនយោបាយការប្រកួតប្រជែងមានលក្ខណៈល្អប្រសើរ។

1.2 សៀវភៅមូលដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងបរិបទនៃភាពផ្សេងគ្នា និងដំណាក់កាលខុសៗគ្នានៃការរៀបចំច្បាប់ប្រកួតប្រជែងនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ សៀវភៅនេះមិនមានបំណងផ្តល់ព័ត៌មានជាក់លាក់ទៅតាមប្រទេសនីមួយៗទេ។

1.3 សៀវភៅមូលដ្ឋាននេះត្រូវបានបង្កើតឡើងដោយចៅក្រមនៃតុលាការសហព័ន្ធអូស្ត្រាលី សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ដោយសហការយ៉ាងជិតស្និទ្ធជាមួយ OECD។ នេះគឺជាសៀវភៅមួយនៅក្នុងចំណោមសៀវភៅមូលដ្ឋានស្តីពីច្បាប់ប្រកួតប្រជែងជាបន្តបន្ទាប់ ដែលត្រូវបានបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់គណៈកម្មការប្រកួតប្រជែងតំបន់ពាណិជ្ជកម្មសេរីអាស៊ានអូស្ត្រាលីនូវែលសេឡង់ (ASEAN Australia New Zealand Free Trade Area Competition Committee) ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program) (‘CLIP’)។

## 2. ទស្សនទាននៃ ‘តួនាទីគ្របដណ្ដប់’ ឬ ‘អំណាចទីផ្សារដ៏ខ្លាំង’

2.1 របបប្រកួតប្រជែងនៅជុំវិញពិភពលោកបានសំដៅទៅរកសញ្ញាណថា ការហាមឃាត់ទៅលើការប្រព្រឹត្តជាឯកតោភាគីគួរអនុវត្តចំពោះតែក្រុមហ៊ុនដែលមាន “អំណាចទីផ្សារដ៏ខ្លាំង” ប៉ុណ្ណោះ។ សកម្មភាពឯកតោភាគីរបស់ក្រុមហ៊ុនមួយដែលមានអំណាចទីផ្សារកម្រិតខ្ពស់កាន់តែងាយធ្វើឱ្យខូចដល់ដំណើរការប្រកួតប្រជែង ហើយមានឥទ្ធិពលដែលប្រឆាំងនឹងការប្រកួតប្រជែង ជាងការប្រព្រឹត្តរបស់ក្រុមហ៊ុនមួយដែលគ្មាន ឬមានអំណាចទីផ្សារតិចតួច។ ក្នុងផ្នែកសេដ្ឋកិច្ច អំណាចទីផ្សារ ជាធម្មតា ត្រូវបានកំណត់ថាជាសមត្ថភាពរបស់ក្រុមហ៊ុនមួយនៅក្នុងការរក្សាតម្លៃផលិតផលមួយរបស់ខ្លួន (ឬផលិតផលច្រើន) ដែលទទួលបានប្រាក់ចំណេញខ្ពស់ជាងតម្លៃប្រកួតប្រជែងក្នុងរយៈពេលយូរអង្វែង។

2.2 ទស្សនទាន និងភាសាផ្សេងៗគ្នាត្រូវបានប្រើនៅជុំវិញពិភពលោកដើម្បីកំណត់កម្រិតអំណាចទីផ្សារ ដែលក្នុងករណីមានការប្រព្រឹត្តហួសពីនេះ ការប្រព្រឹត្តជាឯកតោភាគីនឹងត្រូវបានចាត់ទុកថាបង្ករការខូចខាតដល់ការប្រកួតប្រជែង និងអាចរំលោភបំពានលើច្បាប់ប្រកួតប្រជែង។ នៅអឺរ៉ុប និងក្នុងដែនយុត្តាធិការជាច្រើនផ្សេងទៀតនៅជុំវិញពិភពលោក កម្រិតនេះគឺ ‘តួនាទីគ្របដណ្ដប់’។ ច្បាប់សហព័ន្ធសហរដ្ឋអាមេរិកប្រើកម្រិតនៃ ‘ភាពផ្ដាច់មុខដែលខុសច្បាប់ ឬភាពផ្ដាច់មុខដែលប៉ុនប៉ង’។ កម្រិតរបស់ប្រទេសអូស្ត្រាលីគឺ ‘អំណាចទីផ្សារដ៏ខ្លាំង’។ នៅក្នុងយុត្តាធិការភាគច្រើននៅក្នុងបណ្ដាប្រទេសអាស៊ាន កម្រិតនេះគឺ ‘តួនាទីគ្របដណ្ដប់’។ ទោះបីជាមានភាពខុសគ្នាទាំងនេះក៏ដោយ ក៏របបប្រកួតប្រជែងនៅជុំវិញពិភពលោកបានសំដៅទៅរកសញ្ញាណថាការហាមឃាត់លើការប្រព្រឹត្តឯកតោភាគី គួរតែអនុវត្តចំពោះតែក្រុមហ៊ុនដែលមានអំណាចទីផ្សារដ៏ខ្លាំងប៉ុណ្ណោះ - ដើម្បីងាយស្រួលក្នុងការយល់ កម្រិតនេះនឹងត្រូវហៅថា ‘តួនាទីគ្របដណ្ដប់’ ឬ ‘អំណាចទីផ្សារដ៏ខ្លាំង’ នៅក្នុងសៀវភៅមូលដ្ឋាននេះទាំងមូល។

2.3 ដើម្បីវាយតម្លៃកម្រិតនៃអំណាចដែលក្រុមហ៊ុនមួយកាន់កាប់ក្នុងទីផ្សារ ចាំបាច់ត្រូវកំណត់ទីផ្សារពាក់ព័ន្ធជាមុនសិន។ និយមន័យទីផ្សារផ្ដោតលើតំបន់នៃការប្រកួតប្រជែងជិតស្និទ្ធ ភាពអាចជំនួសគ្នាបានរវាងផលិតផល ឬវិស័យនៃការប្រកួតប្រជែងគ្នារវាងដៃគូប្រកួតប្រជែង ដោយផ្ដោតលើទាំងគំនិតសេដ្ឋកិច្ច និងភាពជាក់ស្ដែងផ្នែកពាណិជ្ជកម្ម។ ឧទាហរណ៍ ប្រសិនបើហាងភីហ្សាតែមួយគត់នៅទីប្រជុំជនដំឡើងថ្លៃរបស់ខ្លួន នោះអតិថិជនអាចប្ដូរទៅប៊ើហ្គឺវិញ ឬហាងភីហ្សាមួយនៅទីប្រជុំជនជិតខាងអាចពង្រីកតំបន់ចែកចាយរបស់ខ្លួន។ ប្រសិនបើការជំនួសទៅប៊ើហ្គឺ និង/ឬអ្នកលក់ភីហ្សានៅទីប្រជុំជនផ្សេងទៀតរារាំងម្ចាស់ហាងភីហ្សានោះពីការដំឡើងថ្លៃដែលផ្ដល់ផលចំណេញច្រើន នោះផលិតផល និងអ្នកលក់ទាំងនោះមុខជានឹងត្រូវបានដាក់បញ្ចូលទៅក្នុងទីផ្សារពាក់ព័ន្ធនោះ។

2.4 យោងតាមឧទាហរណ៍នេះ និយមន័យទីផ្សារ ជារឿយៗនឹងតម្រូវឱ្យចៅក្រមពិចារណាទៅលើផលិតផល (ឧទាហរណ៍ ភីហ្សា និងអាហារចម្អិនរហ័ស) និងភូមិសាស្ត្រ (ឧទាហរណ៍ ទីក្រុងមួយ ទល់នឹងទីក្រុងច្រើន) វិមាត្រ ដាក់បញ្ចូលដោយអនុវត្តគោលការណ៍នេះ៖

a. ការជំនួសផ្នែកខាងតម្រូវការ ដែលជាការជំនួសរវាងទំនិញ ឬសេវាកម្មយោងតាមការយល់ឃើញរបស់អ្នកប្រើប្រាស់ និង

b. នៅក្នុងយុត្តាធិការមួយចំនួន ការជំនួសផ្នែកខាងផ្គត់ផ្គង់ ពោលគឺការជំនួសរវាងទំនិញ ឬសេវាកម្មយោងតាមការយល់ឃើញរបស់អ្នកផ្គត់ផ្គង់។ ការជំនួសផ្នែកខាងផ្គត់ផ្គង់ អាចត្រូវបានពិចារណានៅក្នុងយុត្តាធិការមួយចំនួនសម្រាប់និយមន័យទីផ្សារជាពិសេស ប្រសិនបើឥទ្ធិពលរបស់វាលើឥរិយាបថប្រកួតប្រជែងរបស់អ្នកកាន់កាប់ ស្មើនឹងឥទ្ធិពលនៃការជំនួសផ្នែកខាងតម្រូវការ។ យុត្តាធិការផ្សេងទៀតពិចារណាតែទៅលើការជំនួសផ្នែកខាងផ្គត់ផ្គង់ប៉ុណ្ណោះ នៅពេលវាយតម្លៃលើឥទ្ធិពលនៃការប្រកួតប្រជែង។

2.5 អាស្រ័យលើច្បាប់ប្រកួតប្រជែងពាក់ព័ន្ធ កត្តាតាងនៃចំណុចខាងក្រោមអាចលើកយកមកពិចារណាដោយចៅក្រមនៅក្នុងការវាយតម្លៃតួនាទីគ្របដណ្តប់៖

a. ចំណែកទីផ្សារ រួមមានស្ថិរភាព និងភាពរឹងមាំនៃទីផ្សារ

b. ឧបសគ្គចំពោះការចូល ឬការពង្រីក

c. លទ្ធភាពរបស់អ្នកទិញនៅក្នុងការជះឥទ្ធិពលលើលក្ខខណ្ឌ (អំណាចអ្នកទិញដែលប្រឆាំងតប)

d. លក្ខណៈចរិតទីផ្សារ រួមមានការបើកចំហចំពោះការនាំចូល និង

e. លក្ខណៈចរិតក្រុមហ៊ុន រួមមានទំហំពាក់ព័ន្ធ កម្រិតប្រាក់ចំណេញ ការធ្វើសមាហរណកម្មបញ្ឈរ ធនធានដែលអាចរកបាន និងសេដ្ឋកិច្ចមាត្រដ្ឋាន។

2.6 ការកាន់កាប់តួនាទីគ្របដណ្តប់ ឬអំណាចទីផ្សារដ៏ខ្លាំង មិនត្រូវបានហាមឃាត់តែចំពោះការកាន់កាប់នេះប៉ុណ្ណោះឡើយ។ ច្បាប់ការប្រកួតប្រជែង ជាទូទៅប្រកាសហាមឃាត់តែការប្រព្រឹត្តឯកតោភាគីដែលអាចបង្កអន្តរាយដល់ការប្រកួតប្រជែងតែប៉ុណ្ណោះ ពីព្រោះវានាំឱ្យមានការរំលោភបំពានលើតួនាទីគ្របដណ្តប់។

## 3. ការរំលោភបំពានលើ ‘តួនាទីគ្របដណ្តប់’ ឬ ‘អំណាចទីផ្សារដ៏ខ្លាំង’

3.1 ការរំលោភបំពានលើតួនាទីគ្របដណ្តប់ ត្រូវបានសម្គាល់ដោយការប្រព្រឹត្តដែលផលប៉ះពាល់ ឬឥទ្ធិពលរបស់វាប៉ះពាល់ ឬអាចនឹងប៉ះពាល់ដល់ការប្រកួតប្រជែង។

3.2 ខណៈពេលមានភាពផ្ទុយគ្នាគួរឱ្យកត់សម្គាល់នៅទូទាំងយុត្តាធិការ អំពីវិសាលភាពនៃការប្រព្រឹត្តដែលអាចចាត់ទុកថាជាការរំលោភបំពានលើតួនាទីគ្របដណ្តប់ ឧទាហរណ៍ រួមមាន៖

a. ការកំណត់តម្លៃដែលកេងប្រវ័ញ្ច - តម្លៃទាបដែលមិនមាននិរន្តរភាព មានគោលបំណងដើម្បីលុបបំបាត់ ឬធ្វើឱ្យដៃគូប្រកួតប្រជែងចុះខ្សោយ។

b. ការបដិសេធក្នុងការរកស៊ី ឬការរកស៊ីផ្តាច់មុខ - ការរៀបចំដែលមានគោលបំណងរឹតត្បិតសេរីភាពរបស់ភាគី ក្នុងការសម្រេចចិត្តថាតើពួកគេត្រូវលក់ដូរជាមួយអ្នកណា លក់ដូរអ្វី ឬលក់ដូរនៅកន្លែងណា។

c. គម្រោងចងភ្ជាប់ ចងជាដុំ និងភាពស្មោះត្រង់ - ការភ្ជាប់ការលក់ទំនិញ ឬសេវាកម្ម ដាច់ដោយឡែកពីគ្នាក្នុងគោលបំណងមិនចង់ឱ្យមានការប្រកួតប្រជែង។

d. ការគាបយកកម្រិតចំណេញ - សហគ្រាសរួមបញ្ចូលគ្នាបញ្ឈរ ដែលលក់វត្ថុធាតុចូលសំខាន់ៗទៅគូប្រជែង ដែលធ្វើឱ្យតម្លៃនៅកម្រិតលក់រាយចុះទាប និង/ឬដែលធ្វើឱ្យតម្លៃនៅកម្រិតទីផ្សារឡើងថ្លៃដើម្បី ‘គាបយក’ កម្រិតចំណេញនៅកម្រិតមានប្រយោជន៍តាមទីផ្សារជាក់លាក់ និង

e. ការប្រព្រឹត្តដែលកេងប្រវ័ញ្ចន៍ - កិច្ចព្រមព្រៀងមិនយុត្តិធម៌  ការរើសអើងតម្លៃ ការកាត់បន្ថយផលិតកម្ម ការថ្លៃប្រឌិត ឬគុណភាព។

# 4. ការធ្វើតេស្តផ្លូវច្បាប់ចំពោះការរំលោភបំពាននៃតួនាទីគ្របដណ្តប់

4.1 នៅតាមបណ្តាប្រទេសជាច្រើន មានវិធីសាស្ត្រផ្អែកលើផលប៉ះពាល់ ដោយផ្តោតលើផលប៉ះពាល់សេដ្ឋកិច្ចដែលការប្រព្រឹត្តដែលបានពិនិត្យមានលើអ្នកប្រើប្រាស់ និងការប្រកួតប្រជែង។ ប្រទេសមួយចំនួនទៀតប្រើប្រាស់វិធីសាស្ត្រផ្អែកលើទម្រង់ដែលផ្តោតលើរបៀបដែលការប្រព្រឹត្តនេះអាចត្រូវបានចាត់ថ្នាក់តាមច្បាប់ពាក់ព័ន្ធ។ ក្នុងករណីបែបនេះ ការវិភាគសេដ្ឋកិច្ចនៅតែដើរតួយ៉ាងសំខាន់នៅក្នុងយុត្តាធិការទាំងនោះ ក៏ប៉ុន្តែវាមិនចាំបាច់ដើម្បីអះអាងថា ការប្រព្រឹត្តនោះបានរឹតត្បិតការប្រកួតប្រជែងដើម្បីស្វែងរកការរំលោភច្បាប់នោះទេ។

4.2 ខណៈដែលវិធីសាស្ត្រផ្អែកលើទម្រង់ អាចផ្តល់នូវភាពប្រាកដប្រជាផ្នែកច្បាប់ និងដំណោះស្រាយលឿនជាងវិធីសាស្ត្រផ្អែកលើផលប៉ះពាល់ក្តី វាអាចបង្កើតលទ្ធផលមិនសមស្រប បើគិតពីផលប៉ះពាល់ទីផ្សារជាក់ស្តែងនោះ។ ជាការពិត ការអនុវត្តភាគច្រើន ដែលក្នុងកាលៈទេសៈជាក់លាក់ អាចជាការរំលោភបំពានលើតួនាទីគ្របដណ្តប់ដែលប្រឆាំងនឹងការប្រកួតប្រជែង ក្នុងកាលៈទេសៈផ្សេងទៀតនោះ ក៏អាចមានឥទ្ធិពល ឬប្រសិទ្ធិភាពគាំទ្រការប្រកួតប្រជែងជាទូទៅផងដែរ។

4.3 ឧបករណ៍ប្រើប្រាស់ដើម្បីកំណត់គ្រោះថ្នាក់ដែលអាចកើតមានដល់ការប្រកួតប្រជែង គឺការវិភាគធ្វើឡើងដោយយោងទៅលើការធ្វើតេស្តដែលផ្ទុយនឹងការពិត។

4.4 ការធ្វើតេស្តផ្ទុយការពិត ពាក់ព័ន្ធនឹងការប្រៀបធៀបនៃស្ថានភាពការប្រកួតប្រជែងដែលទំនងជាកើតមាននៅក្នុងទីផ្សារ ដោយមាន ឬគ្មានការប្រព្រឹត្តជាក់លាក់ណាមួយ ដែលបានចោទប្រកាន់ថាជាការរំលោភបំពានលើតួនាទីគ្របដណ្តប់។ ការធ្វើតេស្តនេះក៏អាចមានប្រយោជន៍ផងដែរក្នុងការវាយតម្លៃការបាត់បង់ ឬការខូចខាត។ ការធ្វើតេស្តផ្សេងៗទៀតដែលទីភ្នាក់ងារ និងតុលាការអាចអនុវត្តក្នុងការរំលោភបំពានលើតួនាទីគ្របដណ្តប់ដែលមានស្រាប់៖ ទាំងនេះរួមមានការធ្វើតេស្តការលះបង់ប្រាក់ចំណេញ ការធ្វើតេស្តសេដ្ឋកិច្ចសមហេតុផល ការធ្វើតេស្តក្រុមហ៊ុនដែលមានប្រសិទ្ធិភាពស្មើភាពគ្នា និងការធ្វើតេស្តតុល្យភាពសុខុមាលភាពអ្នកប្រើប្រាស់ផ្សេងៗ។ មានការព្រមព្រៀងជាទូទៅថា គ្មានការធ្វើតេស្តណាមួយដែលសមស្របសម្រាប់គ្រប់ករណីទាំងអស់ឡើយ។

4.5 ការវិភាគផ្ទុយការពិត មិនមែនជាវិទ្យាសាស្ត្រពិតប្រាកដឡើយ។ ក្នុងករណីមួយចំនួន យើងអាចសន្និដ្ឋានថាស្ថានភាពនៃការប្រកួតប្រជែងនៅក្នុងទីផ្សារមួយ មុខជានឹងត្រូវបានរក្សាទុក ក៏ប៉ុន្តែសម្រាប់ការប្រព្រឹត្តដែលកំពុងត្រូវពិចារណា។ ក្នុងករណីផ្សេងទៀត ឧទាហរណ៍ កន្លែងដែលការប្រព្រឹត្តត្រូវបានចោទប្រកាន់ថាបានរារាំងគូប្រជែងថ្មី វាអាចពិបាកក្នុងការទស្សទាយទុកជាមុនដែលគួរឱ្យជឿបាន ថាតើគូប្រជែងថ្មីមុខជានឹងចូលក្នុងទីផ្សារដោយគ្មានការប្រព្រឹត្តដែលកំពុងត្រូវពិចារណាឬក៏អត់ ហើយបើដូច្នេះមែន តើអ្នកចូលថ្មីនោះនឹងមានឥទ្ធិពលអ្វី ដល់ស្ថានភាពប្រកួតប្រជែងនៅក្នុងទីផ្សារពាក់ព័ន្ធនោះ។

4.6 មិនថាតេស្ត ឬស្តង់ដារ ត្រូវបានប្រើដើម្បីកំណត់ថាការប្រព្រឹត្តនោះជាទង្វើខុសច្បាប់ មានយុត្តាធិការជាច្រើនបានបញ្ចប់ការវិភាគដោយពិចារណាលើផលចំណេញដែលមានប្រសិទ្ធភាព ឬយុត្តិកម្មមិនលម្អៀងដែលគួរឱ្យសរសើរ ដូចមានពេលខ្លះ មានមូលហេតុត្រឹមត្រូវ ឬថែមមូលហេតុគាំទ្រការប្រកួតប្រជែង ពីមូលហេតុដែលក្រុមហ៊ុនមានតួនាទីគ្របដណ្តប់ចូលរួមក្នុងការប្រព្រឹត្តនោះ។ យុត្តិកម្មមិនលម្អៀងគឺ កាលៈទេសៈពិសេសចាំបាច់មួយដែលលើកលែងការប្រព្រឹត្តខុសច្បាប់ក្រៅពីនេះ ដូចជាការពិចារណាជាសាធារណៈ (ឧទាហរណ៍ មូលហេតុពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាព)។ ប្រសិទ្ធភាពរួមមាន ឧទាហរណ៍ សេដ្ឋកិច្ច មាត្រដ្ឋាន ឬការលើកទឹកចិត្តនៃការច្នៃប្រឌិត។ វាក៏អាចមានកិច្ចការពារការប្រព្រឹត្តដែលមានបទប្បញ្ញត្តិដែរ ដែលអនុញ្ញាតឱ្យមានអភ័យឯកសិទ្ធិប្រឆាំងនឹងសេចក្តីទុកចិត្ត ដែលការប្រព្រឹត្តត្រូវបានកំណត់ដោយបទប្បញ្ញត្តិសហព័ន្ធ ឬរដ្ឋ។

កិច្ចការពារការប្រព្រឹត្តដែលមានបទប្បញ្ញត្តិធ្វើឱ្យប្រាកដថា រដ្ឋអាចប្រើអំណាចអធិបតេយ្យភាពរបស់ខ្លួនដើម្បីអនុវត្តបទប្បញ្ញត្តិដែលខ្លួនយល់ថាសមហេតុផល ចំពោះហេតុផលសេដ្ឋកិច្ច និង/ឬហេតុផលសង្គម ទោះបីជាបទបញ្ញត្តិនេះអាចផ្ទុយនឹងគោលនយោបាយប្រកួតប្រជែងក៏ដោយ។ ជាធម្មតា នៅក្នុងយុត្តាធិការបែបនេះ បន្ទុកភ័ស្តុតាងវាផ្លាស់ប្តូរ ដូច្នេះវាអាស្រ័យទៅលើក្រុមហ៊ុនដែលកំពុងស្ថិតក្រោមការស៊ើបអង្កេត ដើម្បីបង្ហាញពីអត្ថិភាពនៃប្រសិទ្ធិភាព ឬយុត្តិកម្មមិនលម្អៀងទាំងនេះ ដើម្បីបង្ហាញថាការប្រព្រឹត្តដែលកំពុងត្រូវពិចារណាគឺចាំបាច់ និងមានសមមាត្រ ហើយប្រសិទ្ធភាពបែបនេះមិនអាចសម្រេចបានតាមរយៈមធ្យោបាយប្រឆាំងនឹងការប្រកួតប្រជែងដែលតិចជាងនេះឡើយ។

## 5. ប្រភព និងបញ្ហាអំពីភ័ស្តុតាង

5.1 ដូចរាល់ករណីប្រកួតប្រជែងដែរ តុលាការនឹងអនុវត្តច្បាប់នៃយុត្តាធិការរបស់ខ្លួន និងវិធាននៃភ័ស្តុតាងរបស់ខ្លួនដើម្បីកំណត់ពីលក្ខណៈ និងទំហំនៃភ័ស្តុតាងដែលតម្រូវដើម្បីអះអាងពីការរំលោភបំពាននៃតួនាទីគ្របដណ្តប់។ ប្រភពភ័ស្តុតាងដែលអាចជួយដល់តុលាការ រួមមាន៖

a. ភ័ស្តុតាងពីអ្នកចូលរួម និងអ្នកសង្កេតការណ៍ទីផ្សារ រួមទាំងភ័ស្តុតាងពីអ្នកប្រកួតប្រជែង អ្នកចូលទីផ្សារសក្តានុពល អ្នកផ្គត់ផ្គង់ និងអតិថិជន។

b. ឯកសារផ្ទៃក្នុង និងកំណត់ត្រាអាជីវកម្ម ដូចជាគណនី និងក្រដាសស្នាមរបស់ក្រុមប្រឹក្សា និង

c. ភ័ស្តុតាងអ្នកជំនាញ រួមមានអ្នកជំនាញសេដ្ឋកិច្ច និងឧស្សាហកម្ម។ ភ័ស្តុតាងអ្នកជំនាញត្រូវបានពិភាក្សាលម្អិតបន្ថែមទៀតនៅក្នុងសៀវភៅមូលដ្ឋានស្តីពីការប្រកួតប្រជែងរបស់ CLIP (CLIP Competition Primer) ស្តីពី 'ភ័ស្តុតាងអ្នកជំនាញ'។

5.2 ក្នុងការវាយតម្លៃអំពីតួនាទីគ្របដណ្តប់ តុលាការតែងតែពឹងផ្អែកជាចម្បងលើភ័ស្តុតាងប្រយោលទាក់ទងនឹងរចនាសម្ព័ន្ធទីផ្សារដែលពាក់ព័ន្ធ ដូចជាភ័ស្តុតាងនៃចំណែកទីផ្សារ ឧបសគ្គក្នុងការចូល និងពង្រីក ហើយនិងអំណាចប្រឆាំង។ ភ័ស្តុតាងផ្ទាល់អាចពឹងផ្អែកទៅលើការបន្ថែមភ័ស្តុតាងប្រយោល ក៏ប៉ុន្តែវាទំនងជាមិនអះអាងច្បាស់អំពីតួនាទីគ្របដណ្តប់ឡើយ។ ឧទាហរណ៍ ភ័ស្តុតាងនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន គឺមានប្រយោជន៍តែនៅក្នុងបរិបទប៉ុណ្ណោះ ហើយអាចមានសមត្ថភាពបកស្រាយខុសៗគ្នា។ ការប្រើប្រាស់ភ័ស្តុតាងប្រយោល/ដែលសំអាងទៅលើហេតុការណ៍ ត្រូវបានពិភាក្សាលម្អិតបន្ថែមទៀតនៅក្នុង CLIP Competition Primer) ស្តីពី 'ភ័ស្តុតាងសំអាងលើហេតុការណ៍'។

5.3 ក្នុងករណីខ្លះ ឥទ្ធិពលដែលប្រឆាំងនឹងការប្រកួតប្រជែង ឬឥទ្ធិពលដែលទំនងនោះត្រូវបានបង្កើតឡើងដោយភ័ស្តុតាងផ្ទាល់ដែលអាចទុកចិត្តបាន។ នៅពេលដែលមិនមានភ័ស្តុតាងបែបនេះ ចៅក្រមអាចពឹងផ្អែកលើភ័ស្តុតាងសំអាងលើហេតុការណ៍ និងដំណើរការនៃការទាញសេចក្តីសន្និដ្ឋាន។ វាមិនមែនជារឿងចម្លែកទេដែលការត្រួតស៊ីគ្នាដ៏សំខាន់រវាងភ័ស្តុតាងត្រូវបានប្រើដើម្បីអះអាងពីតួនាទីគ្របដណ្តប់ ហើយដែលធ្លាប់បានប្រើដើម្បីអះអាងពីគោលបំណង ឬផលប៉ះពាល់ដែលទំនងជាកើតឡើង។

5.4 ប្រសិនបើអាច ការគ្រប់គ្រងករណីបែបសកម្មអាចផ្តល់ផលប្រយោជន៍ដល់ចៅក្រម ដែលដោះស្រាយភ័ស្តុតាងស្មុគស្មាញ និងច្រើននៅក្នុងករណីការប្រព្រឹត្តឯកតោភាគី។ ចៅក្រមគួរពិចារណាថាតើមានឧបករណ៍គ្រប់គ្រងករណីអ្វីខ្លះដើម្បីបង្រួមបញ្ហានៅក្នុងវិវាទ គ្រប់គ្រងវិសាលភាព និងទម្រង់នៃភ័ស្តុតាង និងជួយក្នុងការប្រតិបត្តិតាមលំដាប់លំដោយនៃការជំនុំជម្រះក្តី។

## 6. ការសន្មតដោយផ្អែកលើចំណែកទីផ្សារ

6.1 នៅក្នុងយុត្តាធិការមួយចំនួន កម្រិតនៃចំណែកទីផ្សារនៅចុងទាំងពីរនៃវិសាលគមអាចប្រើប្រាស់នៅក្នុងការវិភាគ ថាតើក្រុមហ៊ុនមួយកាន់កាប់តួនាទីគ្របដណ្តប់ ឬអំណាចទីផ្សារដ៏ខ្លាំងឬអត់។

6.2 ចំណែកទីផ្សារជ្រកកោនដែលមានសុវត្ថិភាពអាចត្រូវបានកំណត់ថា ក្រុមហ៊ុនណាមួយដែលមានចំណែកទីផ្សារនៅក្រោមទីជ្រកកោនដែលមានសុវត្ថិភាព នឹងត្រូវបានសន្មតថាមិនកាន់កាប់តួនាទីគ្របដណ្តប់ ឬអំណាចទីផ្សារដ៏ច្រើននោះទេ។

6.3 កម្រិតចំណែកទីផ្សារក៏អាចត្រូវបានកំណត់នៅខាងលើដែរ ដែលក្រុមហ៊ុនមួយនឹងត្រូវបានសន្មតថាកាន់កាប់តួនាទីគ្របដណ្តប់ ឬអំណាចទីផ្សារដ៏ខ្លាំង។

6.4 ទីផ្សារជ្រកកោនដែលមានសុវត្ថិភាព និងកម្រិតតួនាទីគ្របដណ្តប់ដោយផ្អែកលើចំណែកទីផ្សារ អាចបង្កើតការសន្មតដែលអាចសន្និដ្ឋាន ឬឆ្លើយបដិសេធបាន។ ជាទូទៅ ការសន្មតបែបនេះនៅក្នុងយុត្តាធិការភាគច្រើន គឺអាចឆ្លើយបដិសេធបាន។ នេះជាករណីពិសេសសម្រាប់ការសន្មតដែលបង្កើតតួនាទីគ្របដណ្តប់ ពីព្រោះចំណែកទីផ្សារគឺជាឧបករណ៍រិលដែលមិនមានលទ្ធភាពបង្ហាញពីអំណាចទីផ្សារដែលធ្វើឱ្យជឿបាននោះឡើយ។ ដូច្នេះ ចំណែកទីផ្សារខ្ពស់តែម្នាក់ឯងមិនគួរជាភស្តុតាងច្បាស់លាស់ ដែលថាក្រុមហ៊ុនមួយមានអំណាចទីផ្សារដ៏ខ្លាំងនោះទេ ទោះបីការវិភាគចំណែកទីផ្សារអាចជាជំហានដំបូងដ៏មានអត្ថប្រយោជន៍ក្នុងការវិភាគការប្រកួតប្រជែងក៏ដោយ។ ឧទាហរណ៍ ការលើសពីកម្រិតចំណែកទីផ្សារ អាចបង្កើតការសន្មតដែលមិនអាចបដិសេធបាននៃតួនាទីគ្របដណ្តប់ ដោយផ្លាស់ប្តូរបន្ទុកភស្តុតាងពីនិយតករ ទៅក្រុមហ៊ុនប្រព្រឹត្តដែលកំពុងត្រូវពិចារណា។

## 7. ការប្រព្រឹត្តដែលត្រូវបានចាត់ទុកថាជាការរំលោភបំពាននៃតួនាទីគ្របដណ្តប់

7.1 នៅប្រទេសអូស្ត្រាលី ការប្រព្រឹត្តដូចតទៅនេះត្រូវបានរកឃើញដោយតុលាការថាជា ការរំលោភបំពានលើតួនាទីគ្របដណ្តប់៖

a. អ្នកលក់រាយគ្រឿងទេសធំមួយបានបដិសេធមិនព្រមរកស៊ីជាមួយអ្នកផ្គត់ផ្គង់នំប៉័ង ប្រសិនបើនំប៉័ងរបស់ពួកគេក៏ត្រូវបានដាក់លក់ដែរនៅតាមហាងអ្នកលក់រាយគ្រឿងទេសឯករាជ្យនៅក្បែរនោះក្នុងតម្លៃបញ្ចុះថ្លៃ។ ការប្រព្រឹត្តនេះបានបង្កកាន់តែលំបាកដល់អ្នកលក់រាយឯករាជ្យដើម្បីប្រកួតប្រជែងជាមួយអ្នកលក់រាយធំៗ ដើម្បីលក់នំប៉័ងដល់អ្នកប្រើប្រាស់។

b. អ្នកផ្គត់ផ្គង់សេវាកម្មលក់សំបុត្រសម្រាប់ព្រឹត្តិការណ៍សម្តែងកម្សាន្តផ្ទាល់បានបិទ ឬបដិសេធមិនព្រមធ្វើកិច្ចព្រមព្រៀងលក់សំបុត្របញ្ចុះតម្លៃនាទីចុងក្រោយតាមសំណើរបស់អ្នករៀបចំព្រឹត្តិការណ៍ ពីព្រោះសំបុត្រដែលបញ្ចុះតម្លៃត្រូវបានផ្សព្វផ្សាយដោយអ្នកប្រកួតប្រជែងមួយផ្សេងទៀត។ ការប្រព្រឹត្តនេះបានបង្កការលំបាកកាន់តែខ្លាំងសម្រាប់គូប្រកួតប្រជែងដើម្បីលក់សំបុត្របញ្ចុះតម្លៃនាទីចុងក្រោយដល់អតិថិជន។

c. អ្នកផលិតមួយដែលតួនាទីគ្របដណ្តប់នៅក្នុងទីផ្សារលក់វត្ថុរាវគ្មានមេរោគ ក៏ប៉ុន្តែមិនមែននៅក្នុងទីផ្សារលក់វត្ថុរាវលាងឈាម បានផ្តល់ការបញ្ចុះតម្លៃដល់មន្ទីរពេទ្យដែលបានព្រមព្រៀងទិញវត្ថុទាំងពីរមុខរបស់ពួកគេ ដោយដាក់លក់ជាដុំកញ្ចប់។ ការប្រព្រឹត្តនេះបានបង្កកាន់តែលំបាកសម្រាប់អ្នកលក់វត្ថុរាវលាងឈាមផ្សេងទៀត ដើម្បីប្រកួតប្រជែងការលក់នៅមន្ទីរពេទ្យ។

## 8. ការដាក់ទណ្ឌកម្ម និងដំណោះស្រាយ

8.1 មានភាពខុសគ្នាដ៏សំខាន់រវាងទណ្ឌកម្ម និងដំណោះស្រាយ។ ការដាក់ទណ្ឌកម្ម ជាធម្មតាមានបំណងដើម្បីរារាំងដល់ការប្រព្រឹត្តខុសច្បាប់ក្នុងពេលអនាគត ហើយនៅក្នុងយុត្តាធិការមួយចំនួនក៏បង្ខំឱ្យអ្នករំលោភបំពាន ចេញសងនូវផលចំណេញខុសច្បាប់របស់ខ្លួន និងទូទាត់សងដល់ជនរងគ្រោះផងដែរ។ ដំណោះស្រាយគឺដើម្បីប៉ះប៉ូវ កែតម្រូវ ឬការពារការប្រព្រឹត្តខុសច្បាប់ ចំណែកឯទណ្ឌកម្ម វិញគឺដាក់ពិន័យ ឬដាក់ទោស។ ជាធម្មតា ដំណោះស្រាយច្បាប់ការប្រកួតប្រជែង មានគោលបំណងបញ្ឈប់ការប្រព្រឹត្តខុសច្បាប់របស់អ្នករំលោភ ឥទ្ធិពលដែលប្រឆាំងនឹងការប្រកួតប្រជែង និងការកើតឡើងវិញនៃការប្រព្រឹត្តនោះ ហើយអាចព្យាយាមស្តារឡើងវិញនូវដំណើរការប្រកួតប្រជែង។

8.2 ការដាក់ទណ្ឌកម្ម និងដំណោះស្រាយអាចប្រើបានក្នុងករណីមានការរំលោភបំពានលើតួនាទីគ្របដណ្តប់ នឹងអាស្រ័យទៅលើច្បាប់ប្រកួតប្រជែងរបស់យុត្តាធិការពាក់ព័ន្ធ។ អាចមានប្រភេទនៃការដាក់ទណ្ឌកម្ម និងដំណោះស្រាយដូចខាងក្រោមនេះ ៖

a. ដំណោះស្រាយតាមបែបរចនាសម្ព័ន្ធ - ការបញ្ជាឱ្យលះបង់ចោលទាំងមូល ឬផ្នែកណាមួយនៃអាជីវកម្ម ឬទ្រព្យសម្បត្តិជាក់លាក់ដើម្បីស្តារទីផ្សារឱ្យមានស្ថានភាពប្រកួតប្រជែងឡើងវិញ។

b. ដំណោះស្រាយខាងឥរិយាបថ - ការចេញបញ្ជាហាមឃាត់ ឬការបង្ខំឱ្យមានការប្រព្រឹត្តជាក់លាក់ ដើម្បីទប់ទល់នឹងការប្រព្រឹត្តដែលប្រឆាំងនឹងការប្រកួតប្រជែង និងដើម្បីផ្តល់ការណែនាំសម្រាប់ឥរិយាបថនាពេលអនាគត។

c. ការដាក់ពិន័យ - ការដាក់ទណ្ឌកម្មខាងរូបិយវត្ថុ ឬព្រហ្មទណ្ឌ ហើយសំដៅទៅលើអង្គភាពស្របច្បាប់ ឬបុគ្គលដែលទទួលខុសត្រូវ និង

d. ប្រាក់សំណងជំងឺចិត្តចំពោះការខាតបង់ - ការទូទាត់សំណងចំពោះការខាតបង់ ឬការខូចខាតដែលបានកើតឡើងដោយសារការប្រព្រឹត្តចេញសងនូវផលចំណេញដែលទទួលបានពីការប្រព្រឹត្តដែលកំពុងត្រូវពិចារណា។

8.3 ចំណាត់ការដែលដាក់ចេញអាចគិតពិចារណាពីភាពធ្ងន់ធ្ងរ ភាពខ្លាំងក្លា ហើយក្នុងករណីខ្លះ គឺផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃការបំពានផងដែរ។ នៅក្នុងយុត្តាធិការមួយចំនួន សញ្ញាណនៃសមាមាត្រត្រូវបានប្រើដើម្បីធានាថា ចំណាត់ការដែលដាក់ចេញដោយអាជ្ញាធរប្រកួតប្រជែង និងតុលាការ នឹងមិនឈ្លានពានហួសហេតុទៅក្នុងដំណើរការប្រកួតប្រជែងនៅក្នុងទីផ្សារ ឬធ្វើឱ្យខូចទីផ្សារនោះទេ។ វិសាលភាព និងទម្រង់នៃការបន្ធូរបន្ថយសមាមាត្រ មិនគួរលើសពីអ្វីដែលចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃច្បាប់ប្រកួតប្រជែងនោះឡើយ។

8.4 យុត្តាធិការភាគច្រើនអនុញ្ញាតឱ្យតុលាការ និង/ឬភ្នាក់ងារប្រកួតប្រជែង ដាក់បង្ខំឱ្យមានទាំងដំណោះស្រាយតាមបែបរចនាសម្ព័ន្ធ និងដំណោះស្រាយខាងឥរិយាបថ ក៏ប៉ុន្តែខ្លះអនុញ្ញាតឱ្យមានដំណោះស្រាយតាមបែបរចនាសម្ព័ន្ធ តែនៅពេលគ្មានដំណោះស្រាយខាងឥរិយាបថប្រកបដោយប្រសិទ្ធភាពស្មើគ្នាប៉ុណ្ណោះ ឬនៅពេលដែលដំណោះស្រាយដូចនេះណាមួយ អាចជាបន្ទុកធ្ងន់ធ្ងរនៅក្នុងការអនុវត្តតាម ជាងដំណោះស្រាយខាងឥរិយាបថ ។ ក្នុងករណីជាច្រើន ដំណោះស្រាយខាងឥរិយាបថនឹងគ្រប់គ្រាន់ដើម្បីបញ្ចប់ដោយប្រសិទ្ធភាពនៃការរំលោភបំពានលើការប្រកួតប្រជែង។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន ដំណោះស្រាយដែលមានប្រសិទ្ធភាព ឬមានបន្ទុកធ្ងន់ធ្ងរតិចជាង គឺដំណោះស្រាយតាមបែបរចនាសម្ព័ន្ធ។

FEDERAL COURT OF AUSTRALIA

OECD

ASEAN-Australia-New Zealand Free Trade Area (AANZFTA) Economic Cooperation Support Program (AECSP)

## 9. ប្រភពព័ត៌មានពាក់ព័ន្ធ

9.1 ធនធានខាងក្រោមផ្តល់នូវព័ត៌មានបន្ថែមទាក់ទងនឹងការរំលោភបំពានលើតួនាទីគ្របដណ្តប់។ ឯកសារនេះប្រើជាឯកសារយោងទូទៅដ៏មានប្រយោជន៍ សម្រាប់ចៅក្រមនៅក្នុងរដ្ឋជាសមាជិកអាស៊ាន៖

a. គោលនយោបាយតុមូលរបស់ OECD ស្តីពីការប្រកួតប្រជែង (OECD Competition Policy Roundtables)
*បញ្ហាអំពីភ័ស្តុតាងក្នុងការផ្តល់តួនាទីគ្របដណ្តប់* ឆ្នាំ២០០៦

b. OECD Competition Policy Roundtables
*ដំណោះស្រាយ និងការដាក់ទណ្ឌកម្មក្នុងករណីរំលោភលើតួនាទីគ្របដណ្តប់* ឆ្នាំ២០០៦

c. OECD Competition Policy Roundtables
*ការជ្រើសរើសកោនដែលមានសុវត្ថិភាព និងការសន្មតស្របច្បាប់ ក្នុងច្បាប់ប្រកួតប្រជែង* ឆ្នាំ២០១៧

d. បណ្តាញការប្រកួតប្រជែងអន្តរជាតិ (International Competition Network)
*ការអនុវត្តដែលបានអនុសាសន៍ លើការវាយតម្លៃនៃអំណាចទីផ្សារផ្តាច់មុខ/អំណាចទីផ្សារដ៏ខ្លាំង*

e. International Competition Network *សៀវភៅការងារការប្រព្រឹត្តឯកតោភាគី*